# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

## RISK MANAGEMENT IN AMK MICROFINANCE INSTITUTION CREDIT

## ជំនាញ គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

RISK MANAGEMENT IN AMK MICROFINANCE
INSTITUTION CREDIT


សាស្ត្រាចារ្យណែនាំៈ ម៉ុន សៅលី


ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**

**ប្រធានបទ៖ ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

**អេ.អឹម.ខេ**

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត ស្រេង ផល្លា | ប៊ុន សៅលី |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បេក្ខបណ្ឌិត មាស សំណាង |
| ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ | គណៈកម្មការវាយតម្លៃទី៤ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត យ៉ែម សុខហៀក |
| **នាយកវិទ្យាស្ថាន** | នាយិការងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

(Impression)

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ នៅវិទ្យាស្ថានវ៉ាន់ដាអស់រយៈពេល៤ឆ្នាំ សិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យព្រមទាំងមុខវិជ្ជាធនាគារ និងការគ្រប់គ្រងដែលជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តីសុទ្ធតែត្រូវអនុវត្តលើការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាពដូចគ្នាដើម្បីចៀសវាងលើហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងលើស្ថាប័នរបស់ខ្លួន។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថានវ៉ាន់ដា បានបញ្ចូលនូវមុខវិជ្ជាការគ្រប់គ្រងក្នុងកម្មវិធីសិក្សាតាំងពីនៅឆ្នាំមូលដ្ឋានមកម្ល៉េះ ។

គ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារ ការគ្រប់គ្រង និងពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះនឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។ ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះដោយហេតុថា ក្រុមយើងខ្ញុំពុំធ្លាប់មានបទពិសោធន៍ក្នុងការចងក្រងអត្ថបទ ដូចនេះការសិក្សាស្រាវជ្រាវអាចនឹងមានកំហុសឆ្គងលើអត្ថន័យ និងអក្ខរាវិរុទ្ធមួយចំនួនពុំអាចជៀសវាងបានឡើយ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



សួន សុខម៉ី
B21/871



ធន ចាន់ថារីម៉ា
B21/873



ឡេង សុខលាប
B21/884



គន្ធ កនិកា
B21/975



ស្រ៊ី ឡៃហៀក
B21/3000

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ គណនេយ្យ ឆ្នាំទី៤ ជំនាន់ទី២១ វគ្គ៣ នៃវិទ្យាស្ថាន វ៉ាន់ដា

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតចំពោះ**

លោកឳពុក និងអ្នកម្តាយដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងទំនុកបម្រុងគ្រប់បែបយ៉ាង ទាំងផ្នែករូបកាយ និងកម្លាំងចិត្តដល់កូនតាំងពីតូចរហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ លោកទាំងពីរតែងតែខិតខំដោយមិនខ្លាចការនឿយហត់និងមិនរុញរាមួយគ្រាណាឡើយដើម្បីផ្តល់នូវសេចក្តីស្រលាញ់ និងសេចក្តីសុខដល់កូនគ្រប់ពេលវេលា។ ជាពិសេសលោកបានផ្តល់ទ្រព្យសម្បត្តិដ៏មានតម្លៃលើសលប់ គឺចំណេះវិជ្ជាដើម្បីឱ្យកូនក្លាយជាមនុស្សដែលមានចំណេះដឹង និងរមែងអប់រំប្រៀនប្រដៅកូនឱ្យធ្វើជាមនុស្សល្អ និងពលរដ្ឋល្អក្នុងសង្គមជាតិ។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ម៉ុន សៅលី** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញលើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាង និងទទួលខុសត្រូវ លើខ្លឹមសារនៅក្នុងកិច្ចការស្រាវជ្រាវក្រោមប្រធានបទ "**ការគ្រប់គ្រងហានិភ័យក្នុងការផ្ដល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ**" នេះគឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ក្រុមនាងខ្ញុំ ដោយគ្មានពាក់ព័ន្ធជាមួយរបាយការណ៍ សារណា ឬកិច្ចការស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងកិច្ចការស្រាវជ្រាវនេះ គឺថ្មី ហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងកិច្ចការសារណាឬរបាយការណ៍ស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ...........ខែ...........ឆ្នាំ..........ព.ស.២៥៦......

ថ្ងៃទី.........ខែ...........ឆ្នាំ២០២......

ហត្ថលេខាតំណាងក្រុម

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ភីអិលស៊ី មានប្រភពកើតចេញមកពីកម្មវិធីឥណទានខ្នាតតូច និងសន្សំរបស់អង្គការ ខុនស៊ើន វើលវ៉ាយ (Concern Worldwide) ដែលបានបង្កើតដំបូងក្នុងដើមឆ្នាំទសវត្ស ១៩៩០។ ក្នុងឆ្នាំ២០០២ អង្គការ ខុនស៊ើន វើលវ៉ាយ បានសម្រេចចិត្តបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដាច់ដោយឡែកមួយស្ថិតក្រោមឈ្មោះថា អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា (AMK) ដែលបន្ទាប់មកត្រូវបានគេស្គាល់ និងបានចុះបញ្ជីពាណិជ្ជកម្មជា "គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ភីអិលស៊ី"។

សព្វថ្ងៃ គ្រឹះស្ថាន អេ. អឹម. ខេ មានអតិថិជនសរុបជិត ១ លាននាក់ជាមួយនឹងការិយាល័យប្រតិបត្តិការចំនួន ១៥០កន្លែង និងភ្នាក់ងារជិត ៧,០០០កន្លែង នៅទូទាំងប្រទេស។ អេ. អឹម. ខេ មានផលិតផល និងសេវាកម្មជាច្រើនកំពុងផ្តល់ជូនអតិថិជន ដូចជាសេវាប្រាក់កម្ចី ប្រាក់សន្សំ សេវាផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស សេវាធានារ៉ាប់រងខ្នាតតូច។

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ដោយផ្ទាល់របស់ក្រុមយើងខ្ញុំទៅលើប្រធានបទ នៃការគ្រប់គ្រងហានិភ័យឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ រួចមកបានធ្វើឱ្យក្រុមយើងខ្ញុំយល់ដឹងកាន់តែច្បាស់អំពីកត្តាដែលបង្កឱ្យមានហានិភ័យក្នុងការផ្តល់ឥណទានដូចជា កត្តាអតិថិជន កត្តាធនាគារ ព្រមទាំងកត្តាប្រធានសក្តិជាដើម។ ម្យ៉ាងទៀត គ្រឹះស្ថានក៏មានយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យឥណទាន របស់ខ្លួនយ៉ាងល្អិតល្អន់ និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់រាល់ហានិភ័យដែលបានកើតឡើង និងបម្រុងនឹងកើតឡើងនាពេលអនាគតដូចខាងក្រោម៖

- ការបែងចែកការងារជាក់លាក់សម្រាប់អនុប្រធានភ្នាក់ងារឥណទាន និងតំបន់ទទួលខុសត្រូវរបស់ភ្នាក់ងារឥណទាន និងភ្នាក់ងារដោះស្រាយបំណុល
- ការដឹកនាំល្អ និងការបែងចែកការងារជាក់លាក់របស់អនុប្រធាន និងភ្នាក់ងារឥណទានក្នុងការងារឥណទាន
- ប្រព័ន្ធត្រួតពិនិត្យល្អដូចជារបាយការណ៍ត្រួតពិនិត្យគុណភាពឥណទាន
- ការវិភាគល្អលើ ស្ថានភាពបំណុលផ្អែកលើព័ត៌មានដែលបានប្រមូលស្រាវជ្រាវពីភ្នាក់ងារ
- ការបង្កើតជម្រើសដំណោះស្រាយជាច្រើនសម្រាប់ការដោះស្រាយបំណុល
- ការតាមដាន បណ្តុះបណ្តាលត្រឹមត្រូវតាមកាលបរិច្ឆេទ និងកិច្ចសន្យាដែលបានព្រមព្រៀងជាមួយអតិថិជន
- ការបង្កើតនីតិវិធីដោះស្រាយបំណុលដែលបានត្រឹមត្រូវ និងច្បាស់លាស់ ព្រមជាមួយនឹងការផ្តល់ចំណេះដឹង និងការហ្វឹកហ្វឺនជាប្រចាំដល់ភ្នាក់ងារ
- ការធ្វើវិធានការច្បាប់សម្រាប់អតិថិជនដែលមិនសហការទៅតាមកិច្ចសន្យា

ឆ្លងតាមការសិក្សាស្រាវជ្រាវពីប្រធានបទខាងដែលនិយាយអំពី ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ យើងអាចសន្និដ្ឋានបានថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការរីកចម្រើនមកដល់សព្វថ្ងៃនេះ ដោយសារគ្រឹះស្ថានបានពង្រឹង និងអនុវត្តន៍យុទ្ធសាស្ត្រការពារហានិភ័យឥណទានយ៉ាងមានប្រសិទ្ធភាព។

# មាតិកា

ទំព័រ

អារម្ភកថា ....... i

របនាសម្ព័ន្ធ ....... ii

សេចក្តីថ្លែងអំណរគុណ ....... iii

អំណះអំណាង ....... iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ....... v

**ជំពូកទី១**

**សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ....... ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ....... ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ....... ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ....... ២

  ១.៤.១ ទំហំដែនកំណត់ ....... ២

  ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ....... ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ....... ២

  ១.៥.១ ការប្រមូលទិន្នន័យដំបូង ....... ៣

  ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ....... ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ....... ៣

១.៧ របនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... ៣

**ជំពូកទី២**

**ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

២.១ លក្ខណៈទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៥

  ២.១.១ និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៥

  ២.១.២ ប្រវត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៥

  ២.១.៣ លក្ខណៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន ....... ៦

  ២.១.៤ តួនាទីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៦

    ក. តួនាទីអន្តរការី ....... ៦

    ខ. តួនាទីជាអ្នកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ....... ៦

    គ. តួនាទីអភិវឌ្ឍន៍ជនបទ ....... ៦

  ២.១.៥ សមាសភាពនៃការផ្តល់ឥណទាន ....... ៧

២.២ កត្តាដែលបង្ករឱ្យមានហានិភ័យឥណទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... ៧
២.២.១ និយមន័យ ហានិភ័យ ..... ៧
២.២.២ ទ្រឹស្តីពាក់ព័ន្ធនឹងហានិភ័យ ..... ៨
២.៣ យុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... ៨
២.៣.១ និយមន័យ ការគ្រប់គ្រង ..... ៨
២.៣.២ ប្រវត្តិ ការគ្រប់គ្រង ..... ៨
២.៣.៣ ទ្រឹស្តីពាក់ព័ន្ធការគ្រប់គ្រង ..... ៩

## ជំពូកទី៣

## ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

៣.១ ស្ថានភាពទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ..... ១០
៣.១.១ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ..... ១០
៣.១.២ បេសកកម្ម និងទស្សនវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ..... ១៣
ក. ទស្សនៈវិស័យ ..... ១៣
ខ. បេសកកម្ម ..... ១៣
៣.១.៣ រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ..... ១៤
ក.រចនាសម្ព័ន្ធគ្រប់គ្រង ..... ១៤
ខ.ភារកិច្ចគណៈគ្រប់គ្រង ..... ១៥
៣.២ កត្តាដែលបង្ករឱ្យមានហានិភ័យឥណទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ..... ២៤
៣.២.១ កត្តាអតិថិជន ..... ២៤
៣.២.២ កត្តាធនាគារ ..... ២៤
៣.២.៣ កត្តាប្រធានសក្តិ ..... ២៦
៣.៣ យុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ២៦
៣.៣.១ ការបង្កើតផែនការ ..... ២៦
ក. ការចាត់ចែង ..... ២៦
ខ. ការដឹកនាំ ..... ២៦
គ. ការត្រួតពិនិត្យ ..... ២៦
ឃ. លំដាប់លំដោយនៃការដោះស្រាយ ..... ២៧
ង. ការចុះស្រាវជ្រាវដល់មូលដ្ឋាន ..... ២៧
ច. វិភាគលើស្ថានភាពបំណុល ..... ២៧
ឆ. ការបង្កើតជម្រើសដោះស្រាយ ..... ២៧
៣.៣.២ តាមដាននិងត្រួតពិនិត្យ ..... ២៩
៣.៣.៣ នីតិវិធីនៃការដោះស្រាយបំណុល វិធីសាស្ត្រក្នុងការដោះស្រាយបំណុល ..... ២៩

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........................................ ៣១
៤.១ ការវិភាគលើចំណុចខ្សោយ ........................................ ៣២

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................ ៣៣
៥.២ ការផ្តល់អនុសាសន៍ ........................................ ៣៣

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងធ្វើការផ្លាស់ប្តូរ និងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចរបស់ខ្លួនយ៉ាងខ្លាំងពីប្រព័ន្ធសេដ្ឋកិច្ចបែបផែនការឆ្ពោះទៅរកសេដ្ឋកិច្ចបែបទីផ្សារសេរី ដែលជាហេតុធ្វើឱ្យប្រទេសកម្ពុជាឈានចូលដល់ដំណាក់កាលលូតលាស់ និងសកម្មភាពសេដ្ឋកិច្ចកាន់តែរីកដុះដាលឡើង និងនាំឱ្យមានការប្រកួតប្រជែងគ្នាយ៉ាងខ្លាំងនៅលើទីផ្សារធ្វើយ៉ាងណាដើម្បីឱ្យអាជីវកម្មរបស់ពួកគេទទួលបានជោគជ័យ។ ដោយពួកគេត្រូវពឹងផ្អែកទៅលើប្រភពទុនខាងក្នុងនិងក្រៅដែលប្រភពទុនខាងក្នុងជាទុនផ្ទាល់ខ្លួន ចំណែកឯប្រភពទុនខាងក្រៅវិញ បានមកពីការផ្តល់កម្ចីឥណទានរបស់បណ្តាធនាគារ និងស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗ។ ក្នុងនោះផងដែរ សេវាប្រាក់បញ្ញើគឺជាប្រភពទុនដ៏សំខាន់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលផ្តល់ឱ្យអ្នកវិនិយោគអាចធ្វើការសន្សំទុកនូវទុនដើម្បីពង្រីកទុន ឬប្រកបអាជីវកម្មឱ្យកាន់តែរីកចម្រើន។ លើសពីនេះហិរញ្ញវត្ថុ គឺមានសកម្មភាពខ្លាំងក្លាណាស់សម្រាប់សេដ្ឋកិច្ច ព្រោះថាវិស័យនេះបានទាក់ទាញវិនិយោគបន្ថែម រក្សានូវស្ថេរភាពថ្លៃ ម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់ប្រទេសជាតិ។

ដោយយោងទៅតាមជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជានៅតាមបណ្តាខេត្តនានាគឺនូវមានកម្រិតទាបនៅឡើយ ដូច្នេះរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលការណ៍ជម្រុញ និងលើកទឹកចិត្តយ៉ាងខ្លាំងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រោមការជួយជ្រោមជ្រែងពីសំណាក់ធនាគារពិភពលោកដូចជា ធនាគារអភិវឌ្ឍន៍អាស៊ីជាដើម បានធ្វើឱ្យវិស័យមីក្រូហិរញ្ញវត្ថុជាច្រើនបានបង្កើតឡើង ដែលជាផ្នែកមួយសម្រួលដល់ការខ្វះខាតរបស់ប្រជាពលរដ្ឋក្នុងការប្រកបរបរអាជីវកម្មរបស់ពួកគេ។ វិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាបានបន្តអភិវឌ្ឍជាលំដាប់ទាំងចំនួន ទំហំ និងប្រតិបត្តិការក្នុងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យមក៏ដូចជាប្រជាជនតាមតំបន់ដាច់ស្រយាល ដែលមិនទាន់អាចទទួលបាននូវសេវាកម្មហិរញ្ញវត្ថុពីធនាគារពាណិជ្ជ។បន្ថែមពីនេះទៅទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាស្ថាប័នហិរញ្ញវត្ថុដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យហិរញ្ញវត្ថុ ក្នុងការជួយជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិជាពិសេសបានជួយកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជននៅតាមទីជនបទ អ្នកមានជីវភាពខ្វះខាត អ្នកមានចំណូលមធ្យម ដែលបានផ្តល់ឱកាសក្នុងការពង្រីកមុខរបរ ជំនួញ និងអាជីវកម្មខ្នាតតូចរបស់ពួកគេឱ្យកាន់តែប្រសើរឡើង និងរីកចម្រើនទៅមុខ។ ក្នុងនោះ អេ.អឹម.ខេ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ ដែលផ្តល់នូវសេវាហិរញ្ញវត្ថុប្រាក់បញ្ញើដល់អ្នកដែលមានចំណូលទាប មធ្យម ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ពួកគេ។

ជាការពិតណាស់ ការគ្រប់គ្រងហានិភ័យឥណទានមានសារៈសំខាន់សម្រាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការគ្រប់គ្រងហានិភ័យ គឺត្រូវស្វែងយល់វាយតម្លៃ និងតាមដានហានិភ័យផ្សេងៗដែលកើតឡើង។ ដោយឃើញសារៈសំខាន់ពីបញ្ហាខាងលើ ទើបក្រុមនាងខ្ញុំលើកយកប្រធានបទ"**ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ**" មកធ្វើការស្រាវជ្រាវ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងការប្រកបអាជីវកម្មរបស់គ្រឹះស្ថាន ឬធនាគារមួយឱ្យមានការរីកចម្រើនបាន លុះត្រាតែមានការរៀបចំ និងត្រួតពិនិត្យលើការគ្រប់គ្រង ជាពិសេសក្នុងការផ្តល់ឥណទាន ដែលការផ្តល់នេះជាផ្នែកមួយដ៏ធំក្នុងប្រតិបត្តិការទាំងអស់របស់គ្រឹះស្ថានដែលតែងតែជួបប្រទះនូវហានិភ័យខ្ពស់ជាងគេ ។ ស្របជាមួយគ្នានេះដែរ យើងសង្កេតឃើញពីហានិភ័យក្នុងការផ្តល់ឥណទានដោយមានផលប៉ះពាល់លើសេដ្ឋកិច្ច ព្រមទាំងគ្រឹះស្ថានខ្លួនឯងផ្ទាល់ ទើបក្រុមរបស់យើងខ្ញុំបានជ្រើសរើសយកប្រធានបទ " **ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ** " ។

ដោយឃើញបែបនេះហើយ ទើបក្រុមនាងខ្ញុំមានសំណួរចោទសួរមួយចំនួនដូចខាងក្រោម៖

១. តើកត្តាអ្វីខ្លះដែលបង្កឱ្យមានហានិភ័យឥណទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ?

២. តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ មានយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានអ្វីខ្លះ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សានេះមានគោលបំណង ដើម្បីងាយស្រួលដល់ការធ្វើគម្រោងនៃការស្រាវជ្រាវដូចខាងក្រោម៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ
- សិក្សាស្វែងយល់ពីមូលហេតុ និងកត្តានានាដែលបណ្តាលឱ្យមានហានិភ័យឥណទាន
- សិក្សាស្វែងយល់ពីយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យឥណទាន ដូចជាវិធីសាស្ត្រក្នុងការទប់ស្កាត់ និងកាត់បន្ថយហានិភ័យឥណទាន រួមទាំងវិធីសាស្ត្រដោះស្រាយបំណុលមានហានិភ័យ
- ធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ ក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសរសេររបាយការណ៍បញ្ចប់ការសិក្សា ក្រុមយើងខ្ញុំផ្តោតសំខាន់ទៅលើ "ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ" របស់ធនាគារ អេ.អឹម.ខេ សាខាជម្ពូវ័ននៅភូមិជម្ពូវ័ន សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការសរសេររបាយការណ៍បញ្ចប់ការសិក្សា យើងខ្ញុំផ្តោតសំខាន់ទៅលើ « ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ"។ ហើយក្នុងការបកស្រាយនោះទៀត យើងខ្ញុំនឹងប្រើប្រាស់តែទិន្នន័យផ្នែកឥណទានពីរឆ្នាំចុងក្រោយ គឺនៅក្នុងឆ្នាំ២០២១ និង២០២២ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

រាល់កិច្ចការការងារទាំងអស់អាចដំណើរការបានល្អ លុះត្រាតែយើងចេះរៀបចំគម្រោងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់តាមផែនការគ្រោងទុករបស់យើងម្នាក់ៗ ទើបអាចទទួលបានលទ្ធផលយ៉ាងរលូនក្នុងការ

ស្រាវជ្រាវផ្សេងៗ។ ដូច្នេះហើយយើងខ្ញុំបានលើកយកវិធីសាស្ត្រពីរប្រភេទ ដើម្បីធ្វើការប្រមូលព័ត៌មាន គឺតាមរយៈការប្រមូលទិន្នន័យដំបូង និងការប្រមូលទិន្នន័យបន្ទាប់។

**១.៥.១ ការប្រមូលទិន្នន័យដំបូង**

ការប្រមូលទិន្នន័យដំបូង គឺជាការទិន្នន័យដែលប្រមូលបានទាំងស្រុងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេតាមរយៈការចុះទៅធ្វើកិច្ចសម្ភាសន៍ជាមួយក្រុមការងារសំខាន់ៗនៅក្នុងស្ថាប័នទៅតាមខ្លឹមសារអត្ថន័យនៃឯកសារនីមួយៗ ដើម្បីងាយស្រួលក្នុងការសរសេរកិច្ចការស្រាវជ្រាវឱ្យកាន់តែប្រសើរឡើង និងស៊ីជម្រៅ។

**១.៥.២ ការប្រមូលទិន្នន័យបន្ទាប់**

ការប្រមូលទិន្នន័យបន្ទាប់ គឺជាការប្រមូលទិន្នន័យតាមរយៈការស្រាវជ្រាវដូចជា៖

- ការស្វែងរកឯកសារទាក់ទងនឹងប្រធានបទនៅបណ្ណាល័យនានា និងនិក្ខេបបទរៀមច្បង
- ឯកសារទទួលបានពីសាខាជម្ពូវ័ន
- តាមគេហទំព័របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ
- តាមរយៈការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពីទទួលបានការស្រាវជ្រាវទៅលើប្រធានបទ "ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ" យើងខ្ញុំសង្ឃឹមថារបាយការណ៍នេះ នឹងជួយផ្តល់សារៈសំខាន់ដូចខាងក្រោម៖

➢ សម្រាប់គ្រឹះស្ថាន ៖ អាចជួយឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ត្រៀមយុទ្ធសាស្ត្រក្នុងការទប់ទល់ទៅនឹងហានិភ័យក្នុងការផ្តល់ឥណទាន ដែលអាចកើតមានឡើងនាពេលអនាគត និងចេះវិភាគ ថ្លឹងថ្លែងលក្ខខណ្ឌផ្សេងៗ ឱ្យបានល្អិតល្អន់មុននឹងផ្តល់ឥណទានទៅកាន់អតិថិជន ព្រមទាំងអាចជួយគ្រឹះស្ថានដឹងពីចំណុចខ្វះខាតរបស់ខ្លួន។

➢ សម្រាប់កម្មសិក្សាការី ៖ បង្កើនចំណេះដឹងនិងការយល់ដឹងបន្ថែមដែលផ្សារភ្ជាប់រវាងទ្រឹស្តី ដែលបានសិក្សាកន្លងមកនិងការអនុវត្តជាក់ស្តែងក្នុងគ្រឹះស្ថាន។

➢ សម្រាប់សង្គម ៖ជាឯកសារជំនួយដើម្បីជាប្រយោជន៍ដល់សិស្សនិស្សិត និងអ្នកស្រាវជ្រាវជំនាន់ក្រោយយកទៅសិក្សាបន្តនិងទទួលបានចំណេះដឹងបន្ថែមពីឯកសារទាំងនេះ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទ ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ចែកចេញជា ៥ ជំពូកដូចខាងក្រោម៖

➢ **ជំពូកទី១៖ សេចក្តីផ្តើម** លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

➢ **ជំពូកទី២៖ រំលឹកទ្រឹស្តី** ការរំលឹកទ្រឹស្តីដែលមានលក្ខណៈទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមមាននិយមន័យនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ នីតិវិធីឥណទាន និងយុទ្ធសាស្ត្រ។ ប្រវត្តិសង្ខេបទីតាំង

ភូមិសាស្ត្រ ទ្រឹស្តី និងទស្សនៈវិស័យ គោលដៅ វប្បធម៌ការងារ នីតិវិធីនៃការកាត់បន្ថយហានិភ័យឥណទាន ដោះស្រាយឥណទានមានហានិភ័យយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យឥណទាន និងរចនាសម្ព័ន្ធក្នុងការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទាន។

- **ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ** លទ្ធផលស្រាវជ្រាវដែលរួមមានស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ប្រវត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ គោលនយោបាយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ បេសកកម្ម និងទស្សនៈវិស័យរចនាសម្ព័ន្ធរបស់គ្រឹះស្ថានហិរញ្ញវត្ថុ របាយការណ៍លទ្ធផល ភាគហ៊ុននិក និងក្រុមប្រឹក្សាភិបាល។ គោលការណ៍នៃការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទាន ការវាស់វែងហានិភ័យឥណទាន ការវាយតម្លៃទ្រព្យធានា ត្រួតពិនិត្យនៃអត្រាការសងត្រឡប់មកវិញ ការស្វែងយល់សញ្ញាណហានិភ័យឥណទាន លក្ខណៈសម្បត្តិរបស់អតិថិជនដែលអាចទទួលបានឥណទាន ការត្រួតពិនិត្យអត្រាឥណទានដែលមានហានិភ័យ ដំណោះស្រាយនៅពេលអតិថិជនសងបំណុលយឺត ឬមិនសងតាមកាលកំណត់ប្រភេទឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ លក្ខខណ្ឌតម្រូវការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ និងការរៀបចំយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យឥណទាន ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការឈានទៅមុនគេ។
- **ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** ការវិភាគអំពីចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ បន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចមក។
- **ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** សន្និដ្ឋាននិងផ្តល់អនុសាសន៍ផ្សេងៗអំពីចំណុចខ្វះខាតនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ២.១ លក្ខណៈទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ២.១.១ និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

❖ និយមន័យ នៃពាក្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាស្ថាប័នហិរញ្ញវត្ថុដែលផ្តល់សេវាឥណទាន សេវាសន្សំ និង សេវាហិរញ្ញវត្ថុដទៃទៀតដល់អ្នកក្រ។ សេវាហិរញ្ញវត្ថុត្រូវការដោយអ្នកក្រ រួមមាន មូលធនចល័ត ឥណទានអ្នកប្រើប្រាស់ មូលនិធិសោធននិវត្តន៍ ការធានារ៉ាប់រង និងសេវាផ្ទេរប្រាក់។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាការបែងចែកសេវាហិរញ្ញវត្ថុដូចជា កម្ចីនិងប្រាក់បញ្ញើ ដល់អ្នកក្រ អ្នកប្រើប្រាស់ដែលមានចំណូលទាប និងសហគ្រាសធនតូចបំផុត។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាអង្គការមួយប្រភេទដែលផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋក្រីក្រទាំងឡាយ។ ភាគច្រើននៃអង្គការទាំងនេះ ផ្តល់ឥណទានខ្នាតតូចបំផុត និងទទួលប្រាក់បញ្ញើសន្សំតិចតួចពីអ្នកខ្ចីផ្ទាល់របស់ខ្លួន មិនមែនពីសាធារណជនទេ។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាអង្គការមួយប្រភេទដែលផ្តល់សេវាហិរញ្ញវត្ថុដល់អ្នកក្រ ឬអ្នកមានចំណូលទាប។ អង្គការទាំងនោះរួមមាន អង្គការក្រៅរដ្ឋាភិបាលដែលផ្តល់សេវាហិរញ្ញវត្ថុ សហព័ន្ធឥណទាន[1]។

### ២.១.២ ប្រវត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ប្រវត្តិមីក្រូហិរញ្ញវត្ថុ នៅពេលបង្កើតមីក្រូហិរញ្ញវត្ថុដោយសហគ្រិនសង្គមបង់ក្លាដែស Muhammad Yunus ក្នុងឆ្នាំ ១៩៨៣ មីក្រូហិរញ្ញវត្ថុត្រូវបានបង្កើតឡើងក្នុងពេលដំណាលគ្នា។ នៅឆ្នាំ ១៩៨៣ Yunus បានបង្កើតធនាគារ Grameen នៅប្រទេសបង់ក្លាដែស។ គោលដៅរបស់ធនាគារ Grameen គឺដើម្បីផ្តល់ប្រាក់កម្ចីខ្នាតតូចដល់សហគ្រិនដំបូង។ ចក្ខុវិស័យរបស់ Yunus សម្រាប់មីក្រូក្រេឌីតត្រូវបានបំផុសគំនិតនៅពេលដែលគាត់បានឃើញស្ត្រីដែលធ្វើលាមកឬស្សីនៅប្រទេសបង់ក្លាដែសដែលរកបានពីរសេនប៉ុណ្ណោះក្នុងមួយថ្ងៃ។ លោកបានសម្រេចចិត្តថា ប្រសិនបើស្ត្រីអាចខ្ចីប្រាក់វិញ ពួកគេនឹងអាចកែលម្អលើចំណូលរបស់ពួកគេ និងទទួលបានប្រាក់ចំណេញកាន់តែច្រើន។ បន្ទាប់ពីផ្តល់ប្រាក់កម្ចីដល់ពួកគេចំនួន ២៧ ដុល្លារធ្វើតាមគំរូក្រុមស្ត្រីទាំងនោះអាចសងប្រាក់កម្ចី និងបន្តអាជីវកម្មរបស់ពួកគេ។ ទិដ្ឋភាពរបស់មីក្រូហិរញ្ញវត្ថុនៃគណនីសន្សំក៏អាចភ្ជាប់ទៅក្នុងមីក្រូក្រេឌីតផងដែរ ចំណែកឯម្ចាស់បំណុលអាចជ្រើសរើសបញ្ចូលកិច្ចព្រមព្រៀងប្រាក់កម្ចី។ កតិកាសញ្ញាប្រាក់កម្ចីចែងថា អ្នកខ្ចីត្រូវកំណត់ចំណែកនៃប្រាក់ចំណេញនៅក្នុងគណនីសន្សំជាមួយស្ថាប័នហិរញ្ញវត្ថុ ដើម្បីទុកជាវត្ថុបញ្ចាំរហូតដល់ប្រាក់កម្ចីត្រូវបានបង់។ ដូច្នេះវាផ្តល់ការការពារមួយចំនួនសម្រាប់ម្ចាស់បំណុល ហើយប្រសិនបើប្រាក់កម្ចីត្រូវបានសងវិញ អ្នកខ្ចីនឹងទទួលបានការប្រាក់សន្សំលើប្រាក់ដែលបានដាក់ក្នុងគណនីសន្សំ។

[1] https://freshnewsasia.com

ក្នុងឆ្នាំ ២០០៦ លោកYunus បានទទួល រង្វាន់ណូបែលសន្តិភាពសម្រាប់ការខិតខំប្រឹងប្រែងរបស់គាត់ជាមួយធនាគារ Grameen។ ធនាគារបច្ចុប្បន្នគ្រប់គ្រងទីតាំងប្រតិបត្តិការ ២,៥០០ និងជួលបុគ្គលិកប្រហែល ២២,០០០នាក់។ លើសពីនេះ បច្ចុប្បន្នមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន១០,០០០[2] ។

**២.១.៣ លក្ខណៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន**

❖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានលក្ខណៈដូចខាងក្រោម៖

- ជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុស្របច្បាប់ដូចជា ធនាគារពាណិជ្ជ ធនាគារអភិវឌ្ឍន៍ជនបទ និងគ្រឹះស្ថានអន្តរការីមិនមែនធនាគារផ្សេងៗទៀតដែរ។
- រចនាសម្ព័ន្ធនៃភាពជាកម្មសិទ្ធិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចជា រដ្ឋាភិបាល សមាជិក និងអង្គការក្រៅរដ្ឋាភិបាល(NGOs)។
- ជាអ្នកផ្តល់សេវាកម្មផ្តោតទៅលើសេវាមីក្រូហិរញ្ញវត្ថុ ដល់អ្នកក្រ ហើយមួយចំនួនទៀត ផ្តោតទៅលើសេវាកម្មមិនមែនហិរញ្ញវត្ថុដូចជា សេវាអភិវឌ្ឍន៍អាជីវកម្ម (បណ្តុះបណ្តាល និងជំនួយបច្ចេកទេស) ឬសេវាសង្គម(សុខភាព)។
- សេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរួមមាន ឥណទានខ្នាតតូចបំផុតមានដាក់វត្ថុបញ្ចាំ និងគ្មានដាក់វត្ថុបញ្ចាំ សេវាសន្សំ សេវាបញ្ញើ និងសេវាធានារ៉ាប់រង និងសេវាកម្មផ្សេងៗទៀត។
- អតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមមាន ស្ត្រីមេផ្ទះ និវត្តន៍ជន បុគ្គលដែលមិនផ្លាស់ទីកន្លែងបាន កម្មករបាត់បង់ការងារ កសិករក្រីក្រ និងសហគ្រិនធនតូចបំផុត[3]។

**២.១.៤ តួនាទីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

**ក. តួនាទីអន្តរការី**

តួនាទីនេះគឺជា ការអនុវត្តការផ្ទេរប្រាក់សន្សំពីបណ្តាគ្រួសារហើយនឹង បង្វែរពួកវាទៅជា ការផ្តល់ឥណទានឱ្យទៅបណ្តាគ្រួសារ និងបុគ្គល ដើម្បីធ្វើការវិនិយោគជាមួយនឹងគោលដៅបង្កើតប្រាក់ចំណេញ ឬលើកកម្ពស់ជីវភាពរស់នៅ[4]។

**ខ. តួនាទីជាអ្នកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តតាមគោលនយោបាយរូបិយវត្ថុ និងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ដោយចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសគឺការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទឱ្យបានរីកចម្រើន និងបង្កើនស្តង់ដារនៃការរស់នៅរបស់ពលរដ្ឋនៅក្នុងសង្គម។

**គ. តួនាទីអភិវឌ្ឍន៍ជនបទ**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់ ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់កម្ចី ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់សេវាសុខភាព សេវាធានារ៉ាប់រង និងសេវាកម្មផ្សេងៗទៀត។

[2] https://corporatefinanceinstitute.com
[3] https://khemsarith.wordpress.com
[4] តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ – khemsarith (wordpress.com)

នៅក្នុងការអភិវឌ្ឍជនបទគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជា៖

- អ្នកផ្តល់កម្ចីដល់កសិករទាំងឡាយ សម្រាប់ទិញឧបករណ៍និងមធ្យោបាយកសិកម្ម
- អ្នកផ្តល់កម្ចីឱ្យកសិករអាចរក្សាទុកនិងអាចលក់កសិផលរបស់ពួកគេនៅពេលណាដែលមានតម្លៃសមរម្យ
- អ្នកផ្តល់កម្ចីសម្រាប់ បង្កើត ពង្រីក និងកែលម្អមុខរបររបស់កសិករឱ្យបានប្រសើរឡើង
- អ្នកផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈ លើកម្មវិធីផលិតកម្មកសិកម្មដើម្បីឱ្យកសិករចេះរៀបចំ និងអនុវត្តន៍គម្រោងអាជីវកម្មបានត្រឹមត្រូវតាមរយៈនេះអាចបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់កម្ចីតាមគ្រួសារ
- អ្នកកាត់បន្ថយការប្រើប្រាស់កម្ចីដែលមានអត្រាការប្រាក់ខ្ពស់ហួសហេតុដែលមានផលប៉ះពាល់ដល់ស្តង់ដារនៃការរស់នៅរបស់អ្នកទទួលផល។
- អ្នកបង្កើនផលិតផលក្នុងស្រុកតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុ ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចជនបទ។ សេវាមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងពេលបច្ចុប្បន្ននេះរួមមាន ឥណទានក្រុម ការសន្សំប្រាក់ ការហ្វឹកហ្វឺនកសាងសមត្ថភាពដល់អតិថិជន ក្នុងការបង្កើតមុខរបរ ការចុះតាមដាន និងផ្តល់យោបល់ជូនអ្នកខ្ចីប្រាក់ ដើម្បីឱ្យការប្រើប្រាស់មីក្រូឥណទានបានត្រឹមត្រូវនិងមានប្រសិទ្ធភាពខ្ពស់។

#### ២.១.៥ សមាសភាពនៃការផ្តល់ឥណទាន

មានកត្តាជាច្រើន ដែលគួរសម្រេចដោយម្ចាស់បំណុលមុននឹងទទួលយកការសន្យារបស់ អ្នកស្នើសុំដើម្បីសងបំណុលដោយប្រើឥណទានជំនួសសាច់ប្រាក់សុទ្ធ។ ក្នុងនោះគឺមានតែប្រតិបត្តិការឥណទានតែមួយគត់ ដែលអាចកំណត់ភារកិច្ចនេះបានហើយមានការពាក់ព័ន្ធនឹងការទទួលខុសត្រូវពីមន្ត្រីឥណទានដូចខាងក្រោម៖

- ហានិភ័យ
- ពេលវេលា
- ការធានា ឬវត្ថុបញ្ចាំ
- ការឯកភាពតាមច្បាប់
- ចំណាយលើប្រតិបត្តិការ
- អតិផរណា
- បន្ទុកហិរញ្ញវត្ថុ[5]។

### ២.២ កត្តាដែលបង្ករឱ្យមានហានិភ័យឥណទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

#### ២.២.១ និយមន័យហានិភ័យ

- ហានិភ័យ(Risk) គឺជាហេតុឬបញ្ហាប្រឈមផ្សេងៗដែលអាចនាំឱ្យបាត់បង់ឬខូចខាត។
- ហានិភ័យ(Risk) គឺជាកម្រិតនៃគ្រោះថ្នាក់។
- ហានិភ័យ(Risk) គឺជាឱកាសនៃការបាត់បង់។

[5] Robert Cole Loan Misher, Credit Management, 11th Edition

- ហានិភ័យ(Risk) គឺជាឱកាសនៃលទ្ធភាពរបស់លទ្ធផលពិតនៅពេលអនាគត ខុសពីអ្វីដែលគេបានរំពឹងទុក។

### ២.២.២ ទ្រឹស្តីពាក់ព័ន្ធនឹងហានិភ័យ

ហានិភ័យឥណទាន គឺជាហានិភ័យនៃការបាត់បង់ដែលបណ្តាលមកពីការខកខានរបស់ភាគីណាមួយក្នុងការអនុលោមតាមលក្ខខណ្ឌនៃកិច្ចសន្យាហិរញ្ញវត្ថុ ជាពិសេសពីការមិនធ្វើការទូទាត់ចាំបាច់សម្រាប់ប្រាក់កម្ចីដែលជាប់ទាក់ទងនឹងអាជីវកម្ម។ ក្នុងនាមជាឧបករណ៍ហិរញ្ញវត្ថុអាជីវកម្មត្រូវប្រឈមនឹងហានិភ័យជាក់លាក់ចំពោះបរិស្ថានដែលពួកគេធ្វើប្រតិបត្តិការ។ គោលបំណងសំខាន់នៃហិរញ្ញវត្ថុគម្រោងក្នុងការគ្រប់គ្រងហានិភ័យគឺ ត្រូវស្វែងយល់វាយតម្លៃ និងតាមដានហានិភ័យផ្សេងៗដែលកើតឡើង។ ដល់ទីបញ្ចប់នេះអាជីវកម្មត្រូវតែប្រកាន់ខ្ជាប់យ៉ាងតឹងរឹងនូវគោលនយោបាយ ព្រមទាំងនីតិវិធីដែលបានបង្កើតឡើងដើម្បីដោះស្រាយហានិភ័យ។ ដើម្បីវាយតម្លៃហានិភ័យឥណទានអាជីវកម្មគួរតែពិចារណាពីហានិភ័យផ្សេងៗទាក់ទងនឹងអតិថិជន និងវិស័យ[6]។

## ២.៣ យុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ២.៣.១ និយមន័យការគ្រប់គ្រង

- **ការគ្រប់គ្រង** គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព[7]។
- **ការគ្រប់គ្រង** សំដៅលើមុខងារដែលសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់មនុស្សគ្រប់គ្នាដើម្បីសម្រេចបាននូវគោលដៅដោយប្រើប្រាស់ធនធានដែលមានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាព[8]។
- **ការគ្រប់គ្រង** គឺជាដំណើរការនៃការប្រើប្រាស់ធនធាននៅក្នុងអង្គភាពអោយទទួលបានជោគជ័យដល់អង្គភាពដោយមានការរៀបចំការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ[9] ។

### ២.៣.២ ប្រវត្តិការគ្រប់គ្រង

**ការគ្រប់គ្រង** គឺជាពាក្យមួយដែលទូលំទូលាយដោយអាស្រ័យទៅតាមការអនុវត្ត និងការបកស្រាយដោយមនុស្សក្នុងវិស័យផ្សេងៗនៃការងារ។ ចំណែកឯ"ប្រវត្តិនៃការគ្រប់គ្រង" សំដៅជាចម្បងទៅលើប្រវត្តិនៃការគិតរបស់ការគ្រប់គ្រង ដូចដែលវាបានអភិវឌ្ឍន៍ក្នុងអំឡុងពេលនោះ ទោះបីជាការងារខ្លះគ្របដណ្តប់លើការអនុវត្តការគ្រប់គ្រងរហូតទៅដល់សម័យបុរាណក៏ដោយ។ ដោយសារតែព្រឹត្តិការណ៍ អង្គការ ស្ថានភាពសេដ្ឋកិច្ច និងសង្គម នឹងសូម្បីតែអ្នកប្រាជ្ញដែលចាប់អារម្មណ៍ជាញឹកញាប់ដូចគ្នានោះ ប្រវត្តិនៃការគ្រប់គ្រងត្រួតលើគ្នាជាមួយនឹងផ្នែកប្រវត្តិសាស្ត្រដែលពាក់ព័ន្ធ ជាពិសេសប្រវត្តិអាជីវកម្ម ប្រវត្តិសេដ្ឋកិច្ច និងប្រវត្តិគណនេយ្យ។ ប្រវត្តិគ្រប់គ្រងប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រនៃការវិភាគប្រវត្តិសាស្ត្របែបប្រពៃណីក៏ដូចជាការទាញយកការយល់ដឹងពីវិញ្ញាសាធុរកិច្ច និងវិទ្យាសាស្ត្រសង្គម។ អត្ថបទនេះរួមបញ្ចូល ជាដំបូង

[6] https://www.denetim.com/km
[7] https://clubniset.wordpress.com
[8] https://marketbusinessnews-com.
[9] https://www.khsearch.com/qna/24819

ការគ្រប់ដណ្តប់ដំបូងនៃសម្ភារៈប្រភព (ការងារណែនាំ ប្រភពឯកសារយោង និងទិនានុប្បវត្តិ) ហើយបន្ទាប់មកបង្ហាញពីមូលហេតុដែលប្រវត្តិសាស្រ្តមានសារៈសំខាន់ និងផ្តល់នូវការបង្ហាញតាមកាលប្បវត្តិយ៉ាងម៉ត់ចត់នៃការងារសំខាន់ៗសម្រាប់អ្នកដែលចាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែម អំពីប្រវត្តិការគ្រប់គ្រងពីការអនុវត្តដំបូងនៃការគ្រប់គ្រងទៅនឹងការវិវត្តនៃគំនិតគ្រប់គ្រង ដូចដែលវាបានអភិវឌ្ឍន៍ក្នុងអំឡុងពេលមួយរយឆ្នាំកន្លងមក[10]។

### ២.៣.៣ ទ្រឹស្តីពាក់ព័ន្ធការគ្រប់គ្រង

- **ទ្រឹស្តីគ្រប់គ្រង** គឺជាគំនិតជុំវិញយុទ្ធសាស្រ្តគ្រប់គ្រងដែលបានណែនាំ ដែលអាចរួមបញ្ចូលឧបករណ៍ដូចជាក្របខ័ណ្ឌ និងគោលការណ៍ណែនាំដែលអាចត្រូវបានអនុវត្តនៅក្នុងអង្គការទំនើប[11]។

- **ទ្រឹស្តីគ្រប់គ្រង** គឺជាសំណុំនៃច្បាប់ទូទៅដែលណែនាំអ្នកគ្រប់គ្រងឱ្យគ្រប់គ្រងស្ថាប័នមួយ។ ទ្រឹស្តីគ្រប់គ្រង (ត្រូវបានគេស្គាល់ផងដែរថាជា "ទ្រឹស្តីប្រតិបត្តិការ") ផ្តោតលើតួនាទីនៃការគ្រប់គ្រង អង្គការ និងការអនុវត្តជាក្រុម[12]។

[10] https://www.oxfordbibliographies.com.

[11] https://corporatefinanceinstitute.com.

[12] https://www-technofunc-com.

# ជំពូកទី៣
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៣
# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

## ៣.១ ស្ថានភាពទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

### ៣.១.១ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ភីអិលស៊ី មានប្រភពកើតចេញមកពីកម្មវិធីឥណទានខ្នាតតូច និងសន្សំរបស់អង្គការ ខុនស៊ើន វើលវ៉ាយ (Concern Worldwide) ដែលបានបង្កើតដំបូងក្នុងដើមឆ្នាំទសវត្ស ១៩៩០។ ក្នុងឆ្នាំ២០០២ អង្គការ ខុនស៊ើន វើលវ៉ាយ បានសម្រេចចិត្តបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដាច់ដោយឡែកមួយ ស្ថិតក្រោមឈ្មោះថា អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា (AMK) ដែលបន្ទាប់មកត្រូវបានគេស្គាល់ និងបានចុះបញ្ជីពាណិជ្ជកម្មជា "គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ភីអិលស៊ី"។ ការផ្លាស់ប្តូរក្នុងឆ្នាំ ២០០២នេះគឺស្របគ្នានឹងការប្រែប្រួលចំពោះច្បាប់ និងបទប្បញ្ញត្តិរបស់កម្ពុជាក្នុងការគ្រប់គ្រងវិស័យមីក្រូហិរញ្ញវត្ថុ ក៏ដូចជាការវិវត្តក្នុងទីផ្សារវិស័យមីក្រូហិរញ្ញវត្ថុ។ ក្នុងខែកក្កដា ឆ្នាំ២០០៣ គ្រឹះស្ថាន អេ.អឹម.ខេ បានចាប់ផ្តើមប្រតិបត្តិការដោយឯករាជ្យផ្តាច់ចេញពីអង្គការខុនស៊ើនហើយបន្ទាប់មកក៏បានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជាក្នុងឆ្នាំ ២០០៤ ដើម្បីផ្តល់សេវាមីក្រូហិរញ្ញវត្ថុពាសពេញផ្ទៃប្រទេសកម្ពុជា។

មកដល់ត្រឹមឆ្នាំ ២០០៥ គ្រឹះស្ថាន អេ.អឹម.ខេ ទទួលបានប្រាក់ចំណេញប្រតិបត្តិការរបស់ខ្លួនដំបូង ហើយក៏ទទួលបានការអនុម័តទទួលថវិកាជាបំណុលពីខាងក្រៅជាលើកដំបូង និងបានបង្កើតឱ្យមានយន្តការគ្រប់គ្រងលទ្ធផលការងារសង្គម។ នៅក្នុងឆ្នាំបន្ទាប់គ្រឹះស្ថាន អេ.អឹម.ខេ មានកំណើនយ៉ាងឆាប់រហ័សនៅក្នុងអាជីវកម្មស្នូលរបស់ខ្លួនដោយបានពង្រីកបណ្តាញសាខាទៅកាន់គ្រប់ខេត្តក្រុងនៅក្នុងប្រទេស។ គិតត្រឹមឆ្នាំ ២០០៩ គ្រឹះស្ថានបានប្រតិបត្តិការក្នុងគ្រប់ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា ហើយបានក្លាយខ្លួនជាគ្រឹះស្ថានផ្តល់កម្ចីធំជាងគេបង្អស់នៅកម្ពុជា បើយើងគិតទៅលើចំនួនអតិថិជនប្រាក់កម្ចី។

ក្នុងឆ្នាំ ២០១០ គ្រឹះស្ថាន អេ.អឹម.ខេ បានចាប់ផ្តើមធ្វើការកែសម្រួលជាយុទ្ធសាស្រ្តពីអាជីវកម្មដែលផ្តោតតែទៅលើការផ្តល់ឥណទាននៅតាមជនបទ ក្លាយទៅជាគ្រឹះស្ថានមួយដែលផ្តល់សេវាមីក្រូហិរញ្ញវត្ថុទូលំទូលាយជាងមុន។ យុទ្ធសាស្រ្តនេះ ព្រោះយើងចង់ឃើញ អេ.អឹម.ខេ ជាគ្រឹះស្ថានដែលផ្តល់នូវសេវាហិរញ្ញវត្ថុសម្បូរបែបជូនដល់ប្រជាជនក្រីក្រ ក៏ដូចជាបន្តជួយពួកគាត់កែលម្អជីវភាពរស់នៅរបស់ខ្លួន។

ដើម្បីសម្រេចគោលដៅនេះ ក្នុងឆ្នាំ២០១០ គឺជាឆ្នាំដែលជោគជ័យមួយដោយ អេ.អឹម.ខេ ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាថា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI)។

ក្នុងអំឡុងឆ្នាំ២០១១ និង២០១២ ជាមួយនឹងការអនុម័តយល់ព្រមពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថាន អេ.អឹម.ខេ បានចាប់ផ្តើមផ្តល់ជូននូវផលិតផលដាក់ប្រាក់បញ្ញើសន្សំទៅដល់គ្រួសារដែលមានចំណូលទាបតាមរយៈបណ្តាញភ្នាក់ងារ អេ.អឹម.ខេ។ សេវាកម្មនេះផ្តោតជាពិសេសលើគ្រួសារណាដែលពុំអាចមានលទ្ធភាពទទួលបានសេវាកម្មពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ក្នុងឆ្នាំ២០១១ គ្រឹះស្ថាន អេ.អឹម.ខេ បានដាក់ឱ្យប្រើប្រាស់នូវសេវាផ្ទេរប្រាក់ក្នុងស្រុករបស់ខ្លួននៅគ្រប់សាខា និងភ្នាក់ងារជាមួយកម្រៃសេវាដែលមានភាពប្រកួតប្រជែងនៅលើទីផ្សារ។

ក្នុងឆ្នាំ ២០១៣ អេ.អឹម.ខេ បានដាក់ដំណើរការម៉ាស៊ីន អេធីអឹម/ស៊ីឌីអឹម (ATMs/CDMs) នៅគ្រប់សាខារបស់ខ្លួន។

ក្នុងឆ្នាំ២០១៤ អេ.អឹម.ខេ បានចាប់ផ្តើមផ្តល់នូវសេវាធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់បុគ្គល (ដោយសហការជាមួយក្រុមហ៊ុនធានារ៉ាប់រងឯកជនធំបំផុតនៅកម្ពុជា) ដែលភ្ជាប់ទៅនឹងអតិថិជនរបស់ខ្លួនជាដំណាក់កាលសាកល្បងដែលបន្ទាប់មកត្រូវបានពង្រីកសេវានេះទូទាំងប្រទេសក្នុងឆ្នាំ២០១៥។ ជាង ៨០% នៃអតិថិជនរបស់ អេ.អឹម.ខេ បច្ចុប្បន្នទទួលបានសេវាធានារ៉ាប់រងនេះ និងប្រមាណ២៥% បានទិញសេវាធានារ៉ាប់រងបន្ថែមសម្រាប់ស្វាមី/ភរិយា/ដៃគូរបស់ពួកគេ។ ក្នុងឆ្នាំដដែលនោះ គ្រឹះស្ថាន អេ.អឹម.ខេ បានចាប់ផ្តើមផ្តោតសំខាន់ទៅលើវិស័យឌីជីថលផងដែរ។ គម្រោងដំបូងនៅក្នុងអាជីវកម្មរបស់យើង គឺការផ្តល់កម្ចីតាមរយៈឌីជីថល។ អេ.អឹម.ខេ បានអភិវឌ្ឍន៍ប្រព័ន្ធកម្ចីតាមបែបឌីជីថលដោយខ្លួនឯង ដែលអាចឱ្យមន្ត្រីឥណទានធ្វើការងារផ្តល់កម្ចីនៅតាមភូមិជាមួយអតិថិជនរបស់ខ្លួនតាមរយៈតាបប្លេត(Tablet) ចល័ត។ បច្ចុប្បន្នប្រព័ន្ធនេះមិនត្រឹមតែផ្តល់នូវព័ត៌មានល្អប្រសើរជាងមុនប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យមន្ត្រីរបស់យើងងាយស្រួលក្នុងដំណើរការផ្តល់កម្ចីនៅក្នុង អេ.អឹម.ខេ ដែលប្រការនេះអាចកាត់បន្ថយការចំណាយ និងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អតិថិជនប្រសើរជាងមុន។

ក្នុងឆ្នាំ២០១៩/២០២០ អេ.អឹម.ខេ បានដាក់បញ្ចូលប្រព័ន្ធធនាគារស្នូលថ្មីរបស់ខ្លួន និងប្រព័ន្ធស្វីជ (SWITCH) ដែលអាចឱ្យ អេ.អឹម.ខេ អនុវត្តន៍ប្រព័ន្ធឌីជីថលរបស់ខ្លួនកាន់តែប្រសើរជាងមុន និងឆ្លើយតបទៅនឹងការផ្លាស់ប្តូរដ៏ឆាប់រហ័សក្នុងទីផ្សារ។ ប្រព័ន្ធថ្មីនេះបានដាក់ឱ្យដំណើរការនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ នៅគ្រប់សាខានិងតំបន់ប្រតិបត្តិការទាំងអស់របស់គ្រឹះស្ថាន។ ចាប់តាំងពីពេលនោះមក អេ.អឹម.ខេ បានដាក់ឱ្យដំណើរការផលិតផលឌីជីថលថ្មីៗមួយចំនួនដូចជា៖ កម្មវិធីធនាគារចល័តរបស់ អេ. អឹម. ខេ,អេ.អឹម.ខេ ផេ (ការទូទាត់តាមរយៈលេខកូដឃ្យូអ), កម្មវិធីលើទូរស័ព្ទចល័ត ណែនាំអតិថិជន ដោយធ្វើសមាហរណកម្មជាមួយភាគីទីបី ដើម្បីធ្វើការសាកល្បងសំណើរសុំកម្ចីជាលក្ខណៈឌីជីថល ដោយប្រើប្រាស់Chatbot។ លើសពីនេះ អេ.អឹម.ខេ បានធ្វើសមាហរណកម្មយ៉ាងពេញលេញជាមួយប្រព័ន្ធបាគង (ដែលជាបច្ចេកវិទ្យាប្លុកឆេន អនុវត្តដោយធនាគារជាតិនៃកម្ពុជាដែលអនុញ្ញាតឱ្យធនាគារផ្សេងៗដែលមានអាជ្ញាប័ណ្ណអាចប្រើប្រាស់បាន) កម្ពុជាស៊ែរ ស្វិច (Cambodia Share Switch), ការទូទាត់ប្រាក់រហ័ស, និងបានធ្វើសមាហរណកម្មជាមួយអ្នកទូទាត់ប្រាក់ជាង ៣០០ទីតាំងនៅកម្ពុជា។ អេ.អឹម.ខេ បានដាក់ដំណើរការសេវាផ្ទេរប្រាក់ក្រៅប្រទេសដំបូងរបស់ខ្លួន ដោយមានលេខស្វីរ (Swift) និងដៃគូផ្សេងៗដូចជា ធនាគារ ខេ ប៊ី, អេ អឹម ឃ្យូ, ធូន (Thunes), យូញៀនផេ (Unionpay)។

តាមប្រវត្តិសាស្ត្ររបស់ខ្លួន គ្រឹះស្ថាន អេ.អឹម.ខេ បានធ្វើការប្តេជ្ញាចិត្តសម្រេចគោលដៅសង្គម ហើយក្របខណ្ឌគ្រប់គ្រងលទ្ធផលសង្គមបានគ្រប់ជ្រុងជ្រោយ ដើម្បីគ្រឹះស្ថាន អេ.អឹម.ខេ នៅតែបន្តផ្តោតសំខាន់លើបេសកម្មរបស់ខ្លួនក្នុងការជួយគាំទ្រដល់ប្រជាជនកម្ពុជាដែលមានចំណូលទាបជាច្រើននៅកម្ពុជា។ គិតត្រឹមឆ្នាំ២០២១ អេ.អឹម.ខេ មានអតិថិជនសរុបជិត១លាននាក់ជាមួយនឹងការិយាល័យប្រតិបត្តិការ

ចំនួន ១៥០កន្លែង និងភ្នាក់ងារជិត ៧,០០០កន្លែង នៅទូទាំងប្រទេស។ អេ.អឹម.ខេ មានផលិតផល និងសេវាកម្មជាច្រើនកំពុងផ្តល់ជូនអតិថិជន ដូចជាសេវាប្រាក់កម្ចី ប្រាក់សន្សំ សេវាផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស សេវាធានារ៉ាប់រងខ្នាតតូច សេវាទូទាត់វិក្កយបត្រ សេវាបើកប្រាក់បៀវត្ស សេវាបង់រំលស់ ម៉ាស៊ីនដក និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ (ATMs/CDMs) ជាពិសេស គឺ AMK Mobile ប្រតិបត្តិការធនាគារលើទូរស័ព្ទដៃអាចធ្វើការទូទាត់ថ្លៃទឹក ភ្លើង សំរាម បញ្ចូលកាតទូរស័ព្ទ និងបង់វិក្កយបត្រថ្លៃទំនិញផ្សេងៗតាមរយៈការស្កេន KHQR វេរលុយទៅមករវាងធនាគារក្នុងស្រុកផ្សេងៗតាមរយៈប្រព័ន្ធទូទាត់បាគង និងសេវាផ្សេងៗជាច្រើនទៀត។

❖ គោលការណ៍ណែនាំ

- អេ.អឹម.ខេ នឹងផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋក្រីក្រនៅក្នុងប្រទេសកម្ពុជាដែលមានវិន័យហិរញ្ញវត្ថុរឹងមាំនៅគ្រប់កម្រិត
- អេ. អឹម. ខេ ប្តេជ្ញាបើកទូលាយ និងធ្វើឱ្យមានតម្លាភាពគ្រប់ផ្នែកទាំងអស់នៃការគ្រប់គ្រង និងប្រតិបត្តិការ
- អេ. អឹម. ខេ ប្តេជ្ញាអភិវឌ្ឍន៍ដំណើរការសេវាកម្ម និងប្រកាន់ខ្ជាប់នូវអត្តចរិត និងស្តង់ដារដើម្បីធានាឱ្យបានការបម្រើសង្គម ប្រកបដោយប្រសិទ្ធភាពខ្ពស់ដោយរួមទាំងការការពារអតិថិជន
- អេ.អឹម.ខេ គឺជាគ្រឹះស្ថានរៀនសូត្រដែលមានការផ្លាស់ប្តូរ និងការចែករំលែកព័ត៌មានដ៏សមស្រប ដើម្បីរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងចូលរួមចំណែកក្នុងការកែលម្អគោលការណ៍ និងប្រព័ន្ធ។

❖ គ្រឹះស្ថានមីក្រូហិញ្ញវត្ថុ អេ. អឹម. ខេ មានអត្ថសញ្ញាណដូចតទៅៈ

A ស្មើនឹងពាក្យថា (អង្គរ)

M ស្មើនឹងពាក្យថា (មីក្រូហិរញ្ញវត្ថុ)

K ស្មើនឹងពាក្យថា (កម្ពុជា)

➢ អក្សរ A គឺជាការតំណាងឱ្យ ប្រាសាទអង្គរវត្តដែលជាប្រាង្គប្រាសាទដែលរឹងមាំ ហើយជានិមិត្តរូបរបស់ ប្រទេសកម្ពុជា។

➢ អក្សរ M ការតំណាងឱ្យការផ្តល់ប្រាក់កម្ចីខ្នាតមធ្យមមួយដែលអាចជាដើមទុនសំរាប់ប្រជាកសិករ ។

➢ អក្សរ K ការតំណាងឱ្យឈ្មោះរបស់ប្រទេសកម្ពុជា ហើយសំដៅលើការផ្តល់កម្ចីនៅក្នុងស្រុក ។

ពណ៌ស្វាយ គឺការតំណាងឱ្យភាពស្មោះត្រង់ ភក្តីភាព មហិច្ឆតា និងភាពល្អឥតខ្ចោះ។ មិនត្រឹមតែប៉ុណ្ណោះ ពណ៌ស្វាយក៏តំណាងឱ្យភាពច្នៃប្រឌិត សន្តិភាព និងភាពឯករាជ្យ។ កួរស្រូវតំណាងឱ្យការផ្តល់កម្ចីចំពោះប្រជាកសិករដែលមានជីវភាពធុនតូច និងមធ្យម។

ដំបូងឡើយមីក្រូហិរញ្ញវត្ថុមួយនេះមានឈ្មោះថា អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា ដោយហៅកាត់ថា(AMK) ដោយសារតែប្រជាជននៅតាមជនបទ និងនៅតាមតំបន់ទីដាច់ស្រយាលពុំស្គាល់អង្គរមីក្រូហិរញ្ញវត្ថុ។

ដោយសារតែប្រជាពលរដ្ឋតែងតែហៅឈ្មោះកាត់របស់អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជាថា (AMK) ហេតុដូចនេះទើបនាំឱ្យ អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជាបានសម្រេចចិត្តផ្លាស់ប្តូរឈ្មោះទៅជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ថា

អេ. អឹម. ខេ ហើយមានរូបគួរស្រូវនៅកណ្តាលនៃអក្សរជាតិ និងអក្សរបរទេស នៅឆ្នាំ២០០៣ រហូតមកដល់ឆ្នាំ២០១៥។ បន្ទាប់មកនៅឆ្នាំ២០១៦ ក៏សម្រេចចិត្តផ្លាស់ប្តូរនៅផ្លាកសញ្ញាជាថ្មីម្តងទៀតគឺ ប្តូរកួរស្រូវមកដាក់នៅខាងក្រោមនៃអក្សរបរទេស ហើយអក្សរជាតិបានដាក់នៅខាងស្តាំបន្ទាប់ពីអក្សរបរទេស។

**៣.១.២ បេសកកម្ម និងទស្សនវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ**

**ក. ទស្សនវិស័យ**

ទស្សនវិស័យរយៈពេលវែងរបស់ អេ.អឹម.ខេ គឺដើម្បីសង្គមកម្ពុជាដែលប្រជាពលរដ្ឋទាំងឡាយមានឱកាសគ្រប់គ្រាន់ និងស្មើភាពគ្នាក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គមដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ ហើយអាចជួយជាវិភាគទានយ៉ាងមានប្រយោជន៍ចំពោះការអភិវឌ្ឍប្រទេសជាតិ។

**ខ. បេសកកម្ម**

ផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងសម្បូរបែបដល់អតិថិជនគ្រប់រូប ជាពិសេស ស្ត្រី និងគ្រួសារដែលមានចំណូលទាប ដើម្បីជួយសម្រេចបំណងប្រាថ្នាផ្នែកហិរញ្ញវត្ថុ និងជីវភាពដែលពួកគាត់ចង់បាន។

### ៣.១.៣ រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

#### ក. រចនាសម្ព័ន្ធគ្រប់គ្រង

## ក្រុមប្រឹក្សាភិបាល



១.លោក JONH CON-SING YUNGប្រធានក្រុមប្រឹក្សាភិបាល,សមាជិកគណៈកម្មាធិការ SPC និងសមាជិកគណៈកមាធិការRNCG



២.លោក គា បូរាណ ក្រុមព្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ



៣.លោកបណ្ឌិត ទិព្វ ច័ន្ទវិបុល អភិបាលឯករាជ្យ និងប្រធានគណៈកម្មាធិការ វាយតម្លៃ តែងតាំង និងអភិបាលកិច្ច RNCG



៤.លោកស្រី ហេង សិតា ក្រុមប្រឹក្សាភិបាល RCគណៈកម្មាធិការ សវនកម្ម និងហិរញ្ញវត្ថុ AFC



៥.លោកស្រី FANG-HUI HSIEHសមាជិកគណៈកម្មាធិការAFC, និងជាសមាជិក ក្រុមប្រឹក្សាភិបាល ALCO



៦.លោក WEI-KUO YEN ប្រធានគណៈកម្មាធិការហានិភ័យក្រុម ប្រឹក្សាភិបាល RC,សមាជិកគណៈកម្មាធិការ AFC និងALCO



៧.លោក RU-HUNG WEIក្រុមប្រឹក្សាភិបាល ALCO និងជា សមាជិកគណៈកម្មាធិការហានិភ័យក្រុមប្រឹក្សា



៨.លោកស្រី DINA អភិបាលឯករាជ្យ និងប្រធានគណៈកម្មាធិការ ការងារសង្គម SPC



៩.លោកស្រី FRANCES SINHA សមាជិកគណៈកម្មាធិការការងារសង្គម SPC

### ខ. ភារៈកិច្ចគណៈគ្រប់គ្រង

RC

### គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ បានជឿជាក់យ៉ាងមុតមាំទៅលើការគ្រប់គ្រងហានិភ័យថា ពិតជាមានសារៈសំខាន់ណាស់សម្រាប់ជោគជ័យលើអាជីវកម្មក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ទស្សនៈរបស់យើង គឺធានាឱ្យបានថាហានិភ័យទាំងឡាយដែលយើងទទួលយកកំពុងជួយឱ្យគ្រឹះស្ថានសម្រេចបានផែនការយុទ្ធសាស្ត្រ អាជីវកម្ម និងគោលដៅរួមរបស់យើងខណៈពេលកម្រិតហានិភ័យស្ថិតក្រោមការគ្រប់គ្រង និងសមស្រប។ ទំនួលខុសត្រូវខ្ពស់បំផុតសម្រាប់ការកំណត់ហានិភ័យ និងការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធិភាព គឺអាស្រ័យទាំងស្រុងលើក្រុមប្រឹក្សាភិបាល។ ក្នុងតួនាទីដែលផ្តល់ជូនដោយប្រធានក្រុមប្រឹក្សាភិបាល គណៈកម្មាធិការ គ្រប់គ្រងហានិភ័យត្រូវទទួលខុសត្រូវរាល់ការត្រួតពិនិត្យឡើងវិញពីហានិភ័យសហគ្រាសទាំងមូលដែលរួមមានប្រតិបត្តិការអាជីវកម្ម និងយុទ្ធសាស្ត្រការផ្តោតសំខាន់លើគុណភាពផលប័ត្រឥណទាន ការធ្វើផែនការលើដើមទុន សន្ទនីយភាព និងការផ្តល់មូលនិធិ ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការគ្រប់គ្រងហានិភ័យលើកេរ្តិ៍ឈ្មោះស្ថាប័ន និងអនុលោមភាពតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវត្រួតពិនិត្យហានិភ័យ អេ.អឹម.ខេ ទាំងមូល និងផ្តល់ជាអនុសាសន៍ទាំងនេះទៅកាន់ក្រុមប្រឹក្សាភិបាល។ ទំនួលខុសត្រូវនេះរួមបញ្ចូលទាំងការត្រួតពិនិត្យភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពបំផុតនៃប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ អេ.អឹម.ខេ ទាំងមូលដោយពិចារណាលើផលប៉ះពាល់នៃការផ្លាស់ប្តូរបទបញ្ញត្តិ និងកំណើនអាជីវកម្ម អេ.អឹម.ខេ ក្នុងទីផ្សារដែលកំពុងមានភាពប្រកួតប្រជែងនេះ។

នៅក្នុងឆ្នាំ២០២១នេះ គណៈកម្មាធិការគ្រប់គ្រងហានិភ័យបានជួបប្រជុំចំនួន ០៤លើក ដើម្បីចាត់វិធានការសំខាន់ៗក្នុងការបង្កើនលើការគ្រប់គ្រងហានិភ័យឱ្យកាន់តែប្រសើរឡើងនៅក្នុងគ្រឹះស្ថាន។ សមិទ្ធិផលសំខាន់ៗដែលគណៈកម្មាធិការគ្រប់គ្រងហានិភ័យសម្រេចបានក្នុងឆ្នាំ២០២១ មានដូចជា ៖

➢ ត្រួតពិនិត្យលើផលិតផល សកម្មភាព ធ្វើរបាយការណ៍ និងគោលនយោបាយនីតិវិធី សម្រេចបានខាងក្រោម៖

- ការធ្វើវិសោធនកម្មលើគោលនយោបាយធនាគាចល័តការធ្វើវិសោធនកម្មលើគោលនយោបាយបើកប្រាក់បៀវត្ស
- សំណើលើផលិតផលគណនីកូនឆ្លាតឱ្យកាន់តែប្រសើរឡើង
- សំណើលើផលិតផលកម្ចីឱ្យកាន់តែប្រសើរឡើងលើការបង្កើនរយៈពេលកម្ចី

- ការធ្វើវិសោធនកម្មលើគោលនយោបាយផែនការអាជីវកម្ម
- ការធ្វើវិសោធនកម្មលើគោលនយោបាយហានិភ័យឥណទាន
- ចំពោះគណៈកម្មាធិការអនុម័តកម្ចី
- ការធ្វើវិសោធនកម្មលើសូចនាករហានិភ័យសំខាន់ៗនៃ ផលប័ត្រឥណទាន (KRIs)
- ការធ្វើវិសោធនកម្មលើសូចនាករហានិភ័យប្រព័ន្ធព័ត៌មានវិទ្យា (KRIs)
- ការធ្វើវិសោធនកម្មលើគោលនយោបាយប្រព័ន្ធព័ត៌មានវិទ្យា និងស្តង់ដារ
- ការធ្វើវិសោធនកម្មលើសូចនាករការអនុលោមតាម (KRIs)
- ការធ្វើវិសោធនកម្មលើសូចនាករនៃគណៈកម្មាធិការគ្រប់គ្រង
- ទ្រព្យសកម្ម និងបំណុល (KRIs)
- ការធ្វើវិសោធនកម្មលើគោលនយោបាយនៃការគ្រប់គ្រង

➢ សាច់ប្រាក់

- ការធ្វើវិសោធនកម្មលើគោលនយោបាយមូលធនវិនិយោគ អេ.អឹម.ខេ
- ការធ្វើវិសោធនកម្មលើនីតិវិធី ប្រតិបត្តិការស្តង់ដារនៃ AML និង CFT
- ការធ្វើវិសោធនកម្មលើគោលនយោបាយឥណទានអាជីវកម្ម
- ការធ្វើវិសោធនកម្មលើគោលនយោបាយគ្រប់គ្រងភ្នាក់ងារ
- ការធ្វើសំណើរលើភាពជាដៃគូរវាង អេ.អឹម.ខេ និងក្រុមហ៊ុនធានារ៉ាប់រងហូតគេក្នុងទម្រង់ជាកិច្ចសហការភ្នាក់ងារគម្រូ ការធ្វើសំណើជាមួយដៃគូជាលុយក្រៅប្រទេសមានចំនួន៦ក្រុមហ៊ុន
- ការធ្វើសំណើឱ្យកាន់តែប្រសើរឡើងជាមួយដៃគូរវលុយក្រៅ ប្រទេសចំនួន២ដៃគូ
- ការធ្វើសំណើពីការបង្កើនផលប័ត្រឥណទានលើកម្ចីខ្សែសង្វាក់ផលិតកម្ម
- ការធ្វើសំណើលើការបង្កើនរយៈពេលកម្ចីជាក្រុម
- ការធ្វើវិសោធនកម្មលើមូលធនវិនិយោគក្នុង IBF
- ការធ្វើវិសោធនកម្មលើគោលនយោបាយសេវាទូទាត់
- ការធ្វើវិសោធនកម្មលើគោលនយោបាយនៃការចំណាយផ្នែករដ្ឋបាល និងការធ្វើសំណើលើគោលនយោបាយនៃការថែរក្សាទ្រព្យសម្បត្តិ
- ការធ្វើវិសោធនកម្មលើគោលនយោបាយសេវាទំនាក់ទំនង អតិថិជន
- ការធ្វើសំណើពីការបង្កើនដើមទុនជាមួយក្រុមហ៊ុនធានារ៉ាប់រង អាយុជីវិត
- ការធ្វើសំណើពីការបញ្ចប់ភាពជាដៃគូរវាង អេ. អឹម. ខេ និងក្រុមហ៊ុនធានារ៉ាប់រងរហូតទៅ

- ការធ្វើវិសោធនកម្មលើគោលនយោបាយ ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ការធ្វើវិសោធនកម្មលើគោលនយោបាយហានិភ័យប្រតិបត្តិការ
- ការធ្វើសំណើលើផែនការថវិកាសម្រាប់នាយកដ្ឋានគ្រប់គ្រងហានិភ័យ ក្នុងឆ្នាំ២០២២
- ការធ្វើសំណើលើផែនការថវិកាសម្រាប់នាយកដ្ឋានប្រតិបត្តិច្បាប់និងប្រតិបត្តិតាមក្នុងឆ្នាំ២០២២
- ការធ្វើសំណើផលិតផលភតិសន្យាថ្មី"បង់រំលស់លើសម្ភារៈអាជីវកម្ម" ការធ្វើសំណើការដាក់ឱ្យដំណើរ
- ការកម្ចីឯកត្តជនដោយមិនចាំបាច់មានទ្រព្យបញ្ចាំ

ALOC

## គណៈកម្មាធិការ ទ្រព្យសកម្ម និងបំណុល

គណៈកម្មាធិការទ្រព្យសកម្ម និងបំណុលផ្តល់ការប្រឹក្សាពីយុទ្ធសាស្រ្តទាក់ទងនឹងការគ្រប់គ្រងតារាងតុល្យការរបស់ក្រុមហ៊ុនទាំងមូល និងអនុម័តទៅលើគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់ ។ គណៈកម្មាធិការនេះ ទទួលខុសត្រូវលើយុទ្ធសាស្រ្តនៃការគ្រប់គ្រងអត្រាការប្រាក់និងសន្ទនីយភាពហានិភ័យរបស់គ្រឹះស្ថានក្នុងគោលបំណងដើម្បីរក្សាបាននូវកំណើន និងប្រាក់ចំណេញប្រកបដោយនិរន្តភាព និងសម្រេចបាននូវតម្លៃម្ចាស់ភាគហ៊ុនកាន់តែប្រសើរបំផុត។

➢ គណៈកម្មាធិការនេះអនុវត្តភារកិច្ចជាប្រចាំដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញសន្ទនីយភាព និងការគ្រប់គ្រងមូលនិធិរបស់គ្រឹះស្ថាន
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើយុទ្ធសាស្រ្ត មូលនិធិ និងផែនការមូលនិធិបម្រុង
- វាយតម្លៃលើអត្រាការប្រាក់ សន្ទនីយភាព និងហានិភ័យអត្រាប្តូរប្រាក់បរទេសរបស់គ្រឹះស្ថាន
- ត្រួតពិនិត្យឡើងវិញតាមការកំណត់ នៃស្រ្តេសតេស្តទៅលើទីផ្សារសំខាន់ៗ និងផលប៉ះពាល់លើយុទ្ធសាស្រ្តប្រឆាំងការសម្អាតប្រាក់
- ផ្តល់អនុសាសន៍ក្នុងការអនុម័តលើនីតិវិធីទាំងអស់នៃការគាំពារការប្រឆាំងការសម្អាតប្រាក់
- ត្រួតពិនិត្យឡើងវិញការផ្តល់ផលិតផលថ្មី និងការផ្លាស់ប្តូរជាមួយនឹងផលប៉ះពាល់លើប្រាក់ចំណេញ
- សន្ទនីយភាព និង FX position
- ត្រួតពិនិត្យឡើងវិញលើគម្រោងថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្រ្តដែលទាក់ទងទៅនឹងការគ្រប់គ្រងតារាងតុល្យការ

➢ សម្រាប់ឆ្នាំ២០២១នេះ គណៈកម្មាធិការទ្រព្យសកម្ម និងបំណុលបានជួបប្រជុំចំនួន ៤លើក ដើម្បីពិភាក្សាលើបញ្ហាយុទ្ធសាស្ត្រសំខាន់ដែលទាក់ទងនឹងហានិភ័យនៃការគ្រប់គ្រងតារាងតុល្យភាពដូចខាងក្រោម៖

- ត្រួតពិនិត្យការអនុវត្តគម្រោងថវិកានិងការមើលឡើងវិញកំណត់ហានិភ័យហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍ ដែលក្រុមប្រឹក្សាភិបាលនូវយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ
- ត្រួតពិនិត្យផលប៉ះពាល់របស់ Covid-19 ចំពោះការគ្រប់គ្រងទ្រព្យសកម្ម បំណុល និងវាយតម្លៃហានិភ័យសាច់ប្រាក់ងាយស្រួល និងពិនិត្យឡើងវិញព្រមទាំងតាមដានគំរូ Stress Test ។
- ត្រួតពិនិត្យគម្រោងថវិកាឆ្នាំ២០២២ ដោយផ្តោតលើការគ្រប់គ្រងតារាងតុល្យការ និងដាក់ស្នើទៅកាន់ក្រុមប្រឹក្សាភិបាល។
- ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រផ្តល់មូលនិធិ និងការកំណត់តម្លៃក៏ដូចជា ផែនការដើមទុនផ្សេងៗ
- ពិនិត្យពីផលប៉ះពាល់ បទបញ្ញត្តិថ្មីៗ ត្រួតពិនិត្យលើបទបញ្ញត្តិ ដែលមានស្រាប់ស្តីពីការគ្រប់គ្រងហានិភ័យលើតារាងតុល្យការ និងបានផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់លើតារាងតុល្យការ
- ពិនិត្យ និងតាមដានលើហិរញ្ញវត្ថុ និងសូចនាករសន្ទនីភាព និងពិនិត្យក៏ដូចជាផ្តល់អនុសាសន៍នូវផលិតផលតារាងតុល្យការថ្មី ដែលបានចេញក្នុងឆ្នាំ២០២១ ដោយវាយតម្លៃលក្ខណៈផលិតផលសំខាន់ៗដែលជះឥទ្ធិពលដល់ភាពមិនស៊ីគ្នានៃការកំណត់រូបិយប័ណ្ណមិនស៊ីគ្នា និងការប្រាក់។

AFC

### គណៈកម្មាធិការ សវនកម្ម និងហិរញ្ញវត្ថុ

➢ គណៈកម្មាធិការនេះមានទំនួលខុសត្រូវលើចំនុចដូចខាងក្រោម៖

- សុចរិតភាពនៃព័ត៌មានលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានត្រូវបានរាយការណ៍ និងផ្សព្វផ្សាយផ្តល់ព័ត៌មានជូនសាធារណជន និងធនាគារជាតិនៃកម្ពុជាដោយមានភាពត្រឹមត្រូវច្បាស់លាស់ និងជឿជាក់។
- ភាពពាក់ព័ន្ធនៃវិធីសាស្ត្រគណនេយ្យដែលត្រូវបានប្រើប្រាស់ដើម្បីរៀបចំគណនីបុគ្គល និងគណនីរួមបញ្ចូលគ្នា ប្រសិនបើមានគុណភាពនៃប្រព័ន្ធគ្រប់គ្រងសវនកម្មផ្ទៃក្នុងគ្រឹះស្ថាន (នាយកដ្ឋានសវនកម្មផ្ទៃក្នុង) និងឯករាជ្យភាព និងប្រតិបត្តិការនៃសវនករខាងក្រៅរបស់គ្រឹះស្ថាន។

ឞ គណៈកម្មាធិការក៏បានអនុវត្តការងារមួយចំនួនទៀតជាប្រចាំដូចខាងក្រោម៖

- ពិនិត្យ និងពិភាក្សាជាមួយថ្នាក់គ្រប់គ្រងពីបញ្ហារបាយការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងការវិនិច្ឆ័យដែលបានធ្វើឡើងទាក់ទងនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមុនពេលដាក់ជូនក្រុមប្រឹក្សាភិបាលស្ថាប័នរដ្ឋាភិបាលឬសាធារណជន។
- ពិនិត្យ និងផ្តល់អនុសាសន៍លើគោលនយោបាយគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងគោលនយោបាយសវនកម្មផ្ទៃក្នុងសម្រាប់ការអនុម័តរបស់ក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងគ្រប់គ្រងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងផ្តល់អនុសាសន៍លើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដើម្បីក្រុមប្រឹក្សាភិបាលធ្វើការអនុម័ត
- ផ្តល់អនុសាសន៍ និងស្នើថវិកាប្រចាំឆ្នាំដែលបានសុំជាពិសេសលើការចំណាយមូលធន និងចំណាយប្រតិបត្តិការដល់ក្រុមប្រឹក្សាភិបាលសម្រាប់ធ្វើការអនុម័ត។
- ទទួល និងវាយតម្លៃរបាយការណ៍ពីការគ្រប់គ្រងលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលពួកគេបានបង្កើតឡើង
- ពិនិត្យឡើងវិញជាទៀងទាត់នូវ ការសន្និដ្ឋាននៃប្រព័ន្ធសាកល្បងដែលអនុវត្តដោយសវនករផ្ទៃក្នុងឬខាងក្រៅ និងភាពគ្រប់គ្រាន់នៃសកម្មភាពដែលអាចគ្រប់គ្រងបានដោយផ្អែកលើការសន្និដ្ឋានទាំងនោះពិចារណា និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលដើម្បីដាក់ទៅម្ចាស់ភាគហ៊ុនសម្រាប់ការអនុម័តនៅ AGM ទាក់ទងនឹងការតែងតាំងសំណងរបស់សវនករខាងក្រៅ
- ត្រួតពិនិត្យការងាររបស់សវនករខាងក្រៅ និងពិភាក្សាការវិនិច្ឆ័យលើគុណភាព ភាពសមស្រប និងភាពអាចទទួលយកបាននៃគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុន និងការអនុវត្តលើហិរញ្ញវត្ថុភាពពេញលេញ និងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ធានាថាមុខងារសវនកម្មផ្ទៃក្នុងមានធនធានចាំបាច់ និងលទ្ធភាពទទួលបានព័ត៌មានដើម្បីអាចបំពេញបានតាមអាណត្តិរបស់ខ្លួន
- ត្រួតពិនិត្យ និងវាយតម្លៃតួនាទី និងប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុងនៅក្នុងបរិបទទូទៅនៃប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុននៅលើមូលដ្ឋានប្រចាំត្រីមាស ឬយ៉ាងហោចណាស់ពាក់កណ្តាលឆ្នាំ

ឞ ក្នុងឆ្នាំ២០២១ គណៈកម្មាធិការសវនកម្ម និងហិរញ្ញវត្ថុបានជួបប្រជុំចំនួន ០៤លើក ដើម្បីធ្វើការពិភាក្សាលើបញ្ហាយុទ្ធសាស្ត្រខាងក្រោម៖

- ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើរបាយការណ៍សវនកម្មហិរញ្ញវត្ថុ ឆ្នាំ២០២០ សម្រាប់ការអនុម័តពីក្រុមប្រឹក្សាភិបាល

- ពិភាក្សាផែនការសវនកម្មខាងក្រៅឆ្នាំ២០២១ និង២០២២ ជាមួយសវនករខាងក្រៅ
- បានពិភាក្សាអំពីការអនុវត្តខ្សែអាជីវកម្មតក្កវិជ្ជា ការចំណាយថ្លៃដើមផល ចំណេញបន្ទាត់អាជីវកម្មនិងប្រសិទ្ធភាព
- ពិនិត្យវឌ្ឍនភាពប្រឆាំងនិងផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ព្រមទាំងអនុម័តលើផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២២ និងផែនការថវិកាសវនកម្មផ្ទៃក្នុង
- ពិភាក្សាពីការរកឃើញសវនកម្មលើសម្ភារៈ និងផ្តល់ជាមតិយោបល់ក្នុងការកែតម្រូវ និងកែលម្អ
- ត្រួតពិនិត្យ និងអនុម័តលើវិធីសាស្ត្រសវនកម្មទទួលយកដោយផ្អែកលើហានិភ័យដែលបានស្នើឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន
- ពិនិត្យ និងអនុម័តសេចក្តីណែនាំស្តីពីគោលការណ៍ណែនាំអភិវឌ្ឍន៍បុគ្គលិកសវនកម្មផ្ទៃក្នុង តារាងពិន្ទុហានិភ័យសវនកម្មផ្ទៃក្នុងគោលការណ៍ណែនាំហានិភ័យ
- ត្រួតពិនិត្យ និងពិភាក្សាពីផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុដែលបានអនុម័ត និងការអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាថ្មី (CIFRS)
- ពិភាក្សានិងផ្តល់អនុសាសន៍ស្តីពីគម្រោងថវិកាឆ្នាំ២០២២ ដើម្បីអនុម័តពីក្រុមប្រឹក្សាភិបាល។

RNCG

## គណៈកម្មាធិការផ្តល់តម្លៃការ ការតែងតាំង និងអភិបាលកិច្ច

គណៈកម្មាធិការនេះ មានភារកិច្ចត្រួតពិនិត្យជាទូទៅលើផលកម្រៃដែលត្រូវផ្តល់ជូនបុគ្គលិករបស់គ្រឹះស្ថាន និងធានាថាបុគ្គលិកទាំងអស់ទទួលបានអត្ថប្រយោជន៍ និងការទទួលស្គាល់ដ៏ត្រឹមត្រូវផ្អែកលើការរួមចំណែករបស់ពួកគេក្នុងការបំពេញការងារឱ្យគ្រឹះស្ថាន។ គណៈកម្មាធិការនេះក៏ទទួលខុសត្រូវក្នុងការជ្រើសរើសតែងតាំងក្រុមប្រឹក្សាភិបាលថ្មី សមាជិកគណៈកម្មាធិការក្រុម ប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ផងដែរ។ គណៈកម្មាធិការនេះ មានតួនាទីក្នុងការកំណត់គោលនយោបាយសំណងទូទាត់សម្រាប់ក្រុមប្រឹក្សាភិបាល សមាជិកគណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គ្រឹះស្ថាន។ គណៈកម្មាធិការនេះទទួលបន្ទុកណែនាំសមាជិកថ្មីៗ រៀបសេចក្តីសង្ខេប ដើម្បីឱ្យក្រុមប្រឹក្សាភិបាលទទួលបានព័ត៌មានទាន់ពេលវេលាលើការអភិវឌ្ឍផ្នែកអភិបាលកិច្ចគ្រឹះស្ថានធ្វើបច្ចុប្បន្នភាពតួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សាភិបាលទាក់ទងកាតព្វកិច្ចផ្លូវច្បាប់ជាដើម ។ សម្រាប់អភិបាលកិច្ចគ្រឹះស្ថាន គណៈកម្មាធិការនេះត្រូវធានាឱ្យបានថាក្រុមប្រឹក្សាភិបាលបានបំពេញការងារបានយ៉ាងល្អប្រកបដោយប្រសិទ្ធភាព ព្រមទាំងត្រូវអនុវត្តន៍ ឬសម្របសម្រួលក្នុងការវាយតម្លៃសម្រាប់ខ្លួនឯង និងសមាជិកក្នុងក្រុមប្រឹក្សាភិបាលផ្សេងៗទៀតផងដែរ។

៦ នៅក្នុងឆ្នាំ២០២១នេះ គណៈកម្មាធិការផ្តល់តម្លៃការ ការតែងតាំង និងអភិបាលកិច្ចបានជួបគ្នា និងធ្វើកិច្ចប្រជុំចំនួនបីលើក ដើម្បីផ្តល់ជាអនុសាសន៍ទៅកាន់ក្រុមប្រឹក្សាភិបាលលើលទ្ធផលមួយចំនួនដូចជា ៖

- តែងតាំងសមាជិកក្រុមប្រឹក្សាភិបាលថ្មី និងធ្វើការតែងតាំងឡើងវិញសម្រាប់ក្រុមប្រឹក្សាភិបាលដែលមានស្រាប់ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍អំពីការកែប្រែក្របខ័ណ្ឌសមត្ថភាពស្នូល កម្រិតការងារ កម្រិតប្រាក់បៀវត្សសម្រាប់បុគ្គលិក និងថ្នាក់គ្រប់គ្រង អេ.អឹម.ខេ
- ត្រួតពិនិត្យ និងផ្តល់អនុសាសន៍លើគោលនយោបាយប្រាក់លើកទឹកចិត្ត និងអត្ថប្រយោជន៍ផ្សេងៗទៀត
- ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ពីការកែប្រែគោលនយោបាយធនធានមនុស្ស
- ត្រួតពិនិត្យ និងផ្តល់អនុសាសន៍សម្រាប់ការកែប្រែនូវរចនាសម្ព័ន្ធថ្មីរបស់ អេ.អឹម.ខេ។

SPC

## គណៈកម្មាធិការ ការងារសង្គម

នៅកម្រិតក្រុមប្រឹក្សាភិបាល គណៈកម្មាធិការការងារសង្គមជួយក្រុមប្រឹក្សាភិបាល ដើម្បីធានាឱ្យមានការធ្វើយុទ្ធសាស្ត្រ អេ.អឹម.ខេ ឱ្យស្របជាមួយនឹងបេសកកម្មសង្គមរបស់ខ្លួន។ គណៈកម្មាធិការក៏ផ្តល់យោបល់លើភាពអាចជឿជាក់បាននៃក្របខ័ណ្ឌវិភាគ និងរាយការណ៍ដែលត្រូវបានប្រើ ដើម្បីវាស់ស្ទង់ការអនុវត្តការងារសង្គម។ គណៈកម្មាធិការវាយតម្លៃពីផលប៉ះពាល់នៃយុទ្ធសាស្ត្រអាជីវកម្មរបស់ អេ.អឹម.ខេ ដើម្បីសម្រេចបាននូវបេសកកម្មសង្គមរបស់ខ្លួន។ កិច្ចការសំខាន់របស់នាយកដ្ឋានស្រាវជ្រាវគឺដើម្បីជួយគណៈកម្មាធិការការងារសង្គមប្រមូល និងវិភាគទិន្នន័យដល់អតិថិជនគ្រប់កម្រិត(រាប់បញ្ចូលទាំងភាពក្រីក្រ ភាពពេញចិត្ត ហេតុផលចាកចេញ ការប្រើប្រាស់ផលិតផល អាកប្បកិរិយានៃអ្នកប្រើសេវាហិរញ្ញវត្ថុ សមាមាត្រអ្នករស់នៅតាមជនបទ ការយល់ដឹងអំពីផលិតផល មតិយោបល់លើឥរិយាបថរបស់បុគ្គលិក)ដើម្បីជាជំនួយ យុទ្ធសាស្ត្រអាជីវកម្មរបស់ អេ. អឹម. ខេ។ នាយកដ្ឋានស្រាវជ្រាវបានធ្វើការជាមួយ នាយកដ្ឋានផ្សេងៗទៀតនៅ អេ. អឹម. ខេ ដើម្បីធានាឱ្យបានស្តង់ដារ និងការគ្រប់គ្រងការងារសង្គមដែលមានប្រសិទ្ធភាពខ្ពស់។ ទិន្នន័យដែលទទួលបានពីនាយកដ្ឋានស្រាវជ្រាវត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំតាមរយៈ "របាយការណ៍ក្របខ័ណ្ឌការងារសង្គម" ដែលមានបួនចំណុចគឺ ៖ ការផ្សព្វផ្សាយផលិតផល លក្ខណៈពិសេសផលិតផល តម្លាភាព និងការការពារអតិថិជន ព្រមទាំងទំនួលខុសត្រូវរបស់បុគ្គលិក។ របាយការណ៍នេះត្រូវបានបង្ហាញជារៀងរាល់ឆ្នាំដោយគណៈកម្មាធិការការងារសង្គមដល់ក្រុមប្រឹក្សាភិបាល ដើម្បីផ្តល់នូវទស្សនៈមួយប្រកបដោយតុល្យភាពនៃការអនុវត្តការងារ អេ. អឹម. ខេ ដើម្បីអភិបាលកិច្ចធ្វើការសម្រេចចិត្តបានត្រឹមត្រូវទាំងផ្នែកសង្គម និងហិរញ្ញវត្ថុ។

គណៈកម្មាធិការ ការងារសង្គម (SPC) (SPC) មានការប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំដើម្បីពិនិត្យមើលរបាយការណ៍ក្របខ័ណ្ឌការងារសង្គម។

- **គណៈកម្មាធិការ**

❖ កម្រិតគណៈគ្រប់គ្រង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ បានបង្កើតគណៈកម្មាធិការជាច្រើននៅកម្រិតថ្នាក់គ្រប់គ្រង ដើម្បីដោះស្រាយ និងគ្រប់គ្រងលើបញ្ហាផ្សេងៗដែលកើតមាននៅក្នុងប្រតិបត្តិការក្រុមហ៊ុន យោងទៅតាមលក្ខណៈអាជីវកម្ម និងហានិភ័យមួយចំនួនផងដែរ។ គណៈកម្មាធិការទាំងអស់នោះរួមមាន៖

❖ គណៈកម្មាធិការប្រតិបត្តិ (EXCO)

គណៈកម្មាធិការប្រតិបត្តិ (ដឹកនាំដោយប្រធាននាយកប្រតិបត្តិ និងមានការប្រជុំប្រចាំខែ) ទទួលខុសត្រូវលើអាជីវកម្មរបស់ អេ. អឹម. ខេ និងជានាថាគ្រប់ប្រតិបត្តិការទាំងអស់ប្រកបដោយប្រសិទ្ធភាព ។ គណៈកម្មាធិការ មានតួនាទីត្រួតពិនិត្យការងារប្រតិបត្តិសំខាន់ៗ ជាច្រើនរួមមាន យុទ្ធសាស្រ្ត និងការអនុវត្តការគ្រប់គ្រងការងារ បង្កើតគោលនយោបាយ និងគ្រប់គ្រងហានិភ័យផ្សេងៗទៀតដែលអាចកើតឡើងក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្រ្តរបស់ អេ.អឹម.ខេ រួមទាំងហានិភ័យលើកេរ្តិ៍ឈ្មោះស្ថាប័នផងដែរ។

❖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល (MANAGEMENT ALCO)

ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្មនិងបំណុលគឺគ្រប់គ្រងទាំងស្រុងទៅលើតារាងតុល្យការ និងត្រួតពិនិត្យលើផ្នែកហិរញ្ញវត្ថុរបស់ អេ.អឹម.ខេ។ គណៈកម្មាធិការនេះជានាលើអត្រាការប្រាក់ ការកំណត់រូបិយវត្ថុសាច់ប្រាក់ និងហានិភ័យហិរញ្ញវត្ថុដទៃទៀតដែលអាចកើតឡើងចំពោះ ភាពមិនស៊ីសង្វាក់គ្នារវាងទ្រព្យសកម្ម និងបំណុលរបស់ អេ.អឹម.ខេ ហើយត្រូវបានរាយការណ៍ វិភាគ ព្រមទាំងគ្រប់គ្រងយ៉ាងត្រឹមត្រូវ។ ទាំងនេះហើយដែលបានធ្វើឱ្យ អេ.អឹម.ខេ នៅតែបន្តរីកចម្រើនប្រកបដោយនិរន្តភាពទន្ទឹមគ្នានឹងការគ្រប់គ្រងហានិភ័យទាំងឡាយដោយប្រសិទ្ធភាព។

❖ គណៈកម្មាធិការ បច្ចេកវិទ្យាព័ត៌មាន (ITC)

គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មានមានតួនាទីផ្តល់ការណែនាំជាយុទ្ធសាស្រ្តសម្រាប់ការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាទាំងអស់នៅ អេ.អឹម.ខេ។ ជាធម្មតាត្រួតពិនិត្យជាប្រចាំនូវប្រតិបត្តិការព័ត៌មានវិទ្យាច្បាប់ការអនុលោមនៃការអនុវត្តគម្រោង និងយុទ្ធសាស្រ្តប្រតិបត្តិការប្រព័ន្ធព័ត៌មាន។ អាទិភាពនៃការអភិវឌ្ឍ និង ការវិនិយោគប្រព័ន្ធនេះត្រូវតែបំពេញតាមអាទិភាពនៃអាជីវកម្មរបស់ អេ. អឹម. ខេ និងតម្រូវការរបស់អ្នកប្រើប្រាស់។

❖ គណៈកម្មាធិការ អភិវឌ្ឍន៍ផលិតផល (PDC)

គណៈកម្មាធិការអភិវឌ្ឍផលិតផលធានាថា ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ អេ. អឹម. ខេ ត្រូវបានបង្កើតឡើងដោយឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន មានការប្រកួតប្រជែងនៅលើទីផ្សារកាត់បន្ថយហានិភ័យដែលអាចកើតមាន ការចំណាយលើប្រតិបត្តិការមានប្រសិទ្ធភាពខ្ពស់ហើយឆ្លើយតបទៅនឹងចក្ខុវិស័យ និងបេសកកម្មរបស់ អេ.អឹម.ខេ។ គណៈកម្មាធិការនេះក៏មានតួនាទីពិនិត្យ និងសម្រេចទៅលើការបង្កើតផលិតផលទាំងរយៈពេលខ្លី និងរយៈពេលវែង លើកសំណើផ្សេងៗទាក់ទងនឹងផលិតផលថ្មីៗបង្កើតគោលនយោបាយនីតិវិធី និងយុទ្ធសាស្ត្រសម្រាប់ផលិតផល និងសេវាកម្មមុនពេលដាក់បញ្ចូលទៅគណៈកម្មាធិការប្រតិបត្តិ Exco និងក្រុមប្រឹក្សាភិបាល BOD ត្រួតពិនិត្យ និងសម្រេច។ លើសពីនេះទៀត គណៈកម្មាធិការត្រូវតាមដានវឌ្ឍនភាពនៃការអនុវត្ត និងពង្រឹងគម្រោង ធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីគម្រោង ក៏ដូចជារាល់បញ្ហាដែលមិនទាន់សម្រេច (បញ្ហាដែលមិនអាចសម្រេចបានក្នុងក្រុម TFT) វាយតម្លៃភាពជោគជ័យឬបរាជ័យនៃការដាក់ឱ្យប្រើប្រាស់សាកល្បង និងផ្តល់នូវអនុសាសន៍សម្រាប់ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

❖ គណៈកម្មាធិការ គ្រប់គ្រងហានិភ័យ (MRC)

តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ គឺត្រួតពិនិត្យ ការអនុវត្តនៃការគ្រប់គ្រងហានិភ័យរួមនៃផែនការអាជីវកម្មរបស់ក្រុមហ៊ុន។ ហានិភ័យនេះរួមមាន ហានិភ័យប្រតិបត្តិការ ការគ្រប់គ្រងការអនុលោមតាមបទបញ្ញត្តិ និងនីតិវិធីស្តីពីការប្រឆាំងនិងការសំអាតប្រាក់ ក៏ដូចជាហិរញ្ញប្បទានភេរវកម្ម (AML/CFT) រួមទាំងគោលនយោបាយនានា។

❖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ឥណទាន (CRC)

គណៈកម្មាធិការគ្រប់គ្រងហានិភ័យឥណទានមានតួនាទីត្រួតពិនិត្យ និងអនុវត្តការគ្រប់គ្រងហានិភ័យឥណទាន ដែលកើតមានពេលផ្តល់ប្រាក់កម្ចីរួមមាន ការអនុលោមតាមគោលនយោបាយឥណទាន ការផ្តល់ប្រាក់កម្ចី និងការត្រួតពិនិត្យគុណភាពផលប័ត្រប្រាក់កម្ចី។ គណៈកម្មាធិការនេះកំណត់កម្រិតទំហំផលប័ត្រប្រាក់កម្ចី (តាមរយៈផលប័ត្រប្រាក់កម្ចីអតិថិជនតាមវិស័យ ឬ ផលិតផល) ដោយធ្វើការវិភាគលើនិន្នាការ និងមូលហេតុនៃការមិនបំពេញកាតព្វកិច្ចរបស់អតិថិជនកម្ចី ព្រមទាំងចាត់វិធានការបង្ការនៅពេលចាំបាច់។

❖ គណៈកម្មាធិការ យុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានវិទ្យា (ITSC)

គោលបំណងនៃគណៈកម្មាធិការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន គឺធានាថាផែនការ និងយុទ្ធសាស្ត្រនៃប្រព័ន្ធបច្ចេកវិទ្យា គឺត្រូវតែផ្តល់សេវាកម្ម និងដំណោះស្រាយប្រកបដោយស្តង់ដារបច្ចេកវិទ្យា និងគោលការណ៍ត្រឹមត្រូវ។

❖ គណៈកម្មាធិការ គ្រប់គ្រងសាខា (BMC)

គណៈកម្មាធិការគ្រប់គ្រងសាខាត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងដំណើរការសាខាទាំងអស់ អេ.អឹម.ខេ ហើយធានាបាននូវគុណភាពប្រសិទ្ធភាពតាមរយៈការលើកកម្ពស់សេវាកម្មអតិថិជនប្រកបដោយស្តង់ដារ និងសម្រេចបានលទ្ធផលនៃការអនុវត្តការងារខ្ពស់។ គណៈកម្មាធិការនេះក៏មានទំនួលខុសត្រូវក្នុងការជ្រើសរើសតំបន់សក្តានុពលដើម្បីបើកសាខាថ្មី និងផ្តល់សេវាធនាគាររហ័សឱ្យស្របទៅតាមទិសដៅយុទ្ធសាស្រ្តអាជីវកម្ម អេ.អឹម.ខេ ផងដែរ។

❖ គណៈកម្មាធិការ រៀនសូត្រ និងអភិវឌ្ឍន៍ (LDC)

គណៈកម្មាធិការរៀនសូត្រ និងអភិវឌ្ឍន៍ (LDC) ទទួលខុសត្រូវក្នុងការណែនាំជាយុទ្ធសាស្រ្តសម្រាប់ការគ្រប់គ្រងរៀបចំ កម្មវិធីបណ្តុះបណ្តាលទាំងអស់ក្នុង អេ.អឹម.ខេ។ គណៈកម្មាធិការនេះមានសិទ្ធក្នុងការសម្រេចចិត្តលើគ្រប់ផ្នែកដែលទាក់ទងជាមួយនឹងកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាព ក្នុង អេ.អឹម.ខេ។ ជាងនេះទៅទៀត គណៈកម្មាធិការនេះមានកាតព្វកិច្ចក្នុងការផ្តល់អនុសាសន៍ទៅកាន់គណៈកម្មាធិការប្រតិបត្តិ ក្នុងករណីចាំបាច់ដែលត្រូវដែលធ្វើការកែលម្អបន្ថែមក្នុងគ្រឹះស្ថាន។

## ៣.២ កត្តាដែលបង្ករឱ្យមានហានិភ័យឥណទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

### ៣.២.១ កត្តាអតិថិជន

- អតិថិជនមានបំណងមិនសងបំណុលដល់គ្រឹះស្ថាន
- មានបញ្ហាលើមុខរបរ ឬបាត់បង់ទ្រព្យសម្បត្តិ
- អតិថិជនមិនគោរពលក្ខខណ្ឌនានាដែលបានចែងក្នុងកិច្ចសន្យា
- មានភាពឆោតល្ងង់ក្នុងការឈរឈ្មោះខ្ចីប្រាក់ឱ្យភាគីទី៣ ឬអ្នកដាក់ធានាជំនួស
- ប្រើប្រាស់ប្រាក់កម្ចីហួតលើសសមត្ថភាពសង ។

### ៣.២.២ កត្តាធនាគារ

- បុគ្គលិកធ្វេសប្រហែសក្នុងការវាយតម្លៃប្រាក់កម្ចី
- សមត្ថភាពបុគ្គលិកនៅមានកម្រិតលើការវាយតម្លៃប្រាក់កម្ចី ជាពិសេសក្នុងការរកឱ្យឃើញប្រាក់កម្ចីជាន់គ្នា
- បុគ្គលិកចង់បានប្រាក់រង្វាន់លើកទឹកចិត្ត មិនផ្តោតលើគុណភាព
- បុគ្គលិកទទួលអត្ថប្រយោជន៍ពីអតិថិជន
- បុគ្គលិកពន្យល់ពីគោលការណ៍ឥណទានមិនបានស៊ីជម្រៅដល់អតិថិជន
- បុគ្គលិកផ្តល់កម្ចីតាមមេខ្យល់ មេក្រុម ឬឈ្មួញកណ្តាល
- បុគ្គលិកមានចេតនាដាក់ប្រាក់កម្ចីជាន់គេ ( មានបញ្ហាជាមួយស្ថាប័នខ្លួនឯង ឬចង់ឈ្នះស្ថាប័នដទៃ )
- មិនបានពិគ្រោះយោបល់ជាមួយអតិថិជនក្នុងការខ្ចីប្រាក់កម្ចីប្រើប្រាស់

- ចង់សម្រេចតាមផែនការដែលថ្នាក់លើដាក់ឱ្យ
- មិនធ្វើការសិក្សាលើអតិថិជនចាស់
- ខ្វះការទំនាក់ទំនងជាមួយល្អជាមួយអាជ្ញាធរមូលដ្ឋានក្នុងការប្រមូលព័ត៌មាន
- ផ្តល់ប្រាក់កម្ចីហើយមិនបានត្រួតពិនិត្យតាមដានការប្រើប្រាស់ប្រាក់កម្ចី និងក្រើនរំលឹកអតិថិជនក្នុងការសងប្រាក់
- ផ្តល់កម្ចីដល់តំបន់ដែលគ្មានសក្តានុពល
- ខ្វះប្រព័ន្ធត្រួតពិនិត្យ( ថ្នាក់គ្រប់គ្រងមិនបានដឹងពីបញ្ហាដែលកើតឡើងទាន់ពេលវេលា )
- ខ្វះការលើកទឹកចិត្តបុគ្គលិក (បុគ្គលិកមិនយកចិត្តទុកដាក់ក្នុងការជ្រើសរើសអតិថិជន )
- គោលការណ៍ នីតិវិធីក្នុងការផ្តល់កម្ចីមិនសូវតឹងរឹង ( ខ្សោយក្នុងការជ្រើសរើសអតិថិជន )
- មិនមានការយកចិត្តទុកដាក់ក្នុងការដោះស្រាយហួសកាលកំណត់ (កម្ចីមានបញ្ហាមិនត្រូវបានដោះស្រាយឱ្យទាន់ពេលវេលា )
- ខ្សោយក្នុងការត្រួតពិនិត្យឥណទាន
- ខ្វះព័ត៌មានដែលពាក់ព័ន្ធ (ផ្តល់ប្រាក់កម្ចីដល់អតិថិជនច្រើនហួស )
- អនុវត្តន៍ប្រាសចាកពីគោលនយោបាយនីតិវិធី និងសេចក្តីណែនាំអំពីការផ្តល់ឥណទាន
- ភ្នាក់ងារឥណទាន ធ្វើការគ្មានផែនការច្បាស់លាស់ដោយមិនគោរពទៅតាមការណាត់
- សិក្សាតំបន់ និងរដូវកាលមិនច្បាស់លាស់
- មិនសិក្សាឱ្យបានស៊ីជម្រៅអំពីអត្តចរិតរបស់អតិថិជន
- សិក្សាមិនបានស៊ីជម្រៅលើលំហូរសាច់ប្រាក់របស់អតិថិជន
- សិក្សាមិនបានស៊ីជម្រៅពីសក្តានុពលមុខរបរលើទីផ្សាររបស់អតិថិជន
- សិក្សាមិនបានច្បាស់លាស់អំពីទ្រព្យសម្បត្តិ និងដើមទុនរបស់អតិថិជនដោយផ្តល់ឥណទានឱ្យដោយមនោសញ្ចេតនា
- ផ្តល់ឥណទាននៅតាមតំបន់ខូចច្រើនដែលមិនទាន់បានចាត់វិធានការដោះស្រាយ មិនបានសិក្សាអំពីប្រវត្តិសងប្រាក់ច្បាស់លាស់
- ធ្វេសប្រហែសដោយយកចិត្តទុកដាក់លើអតិថិជនចាស់មិនវាយតម្លៃសាថ្មីចំពោះការផ្តល់ឥណទានបន្ត
- ភ្នាក់ងារឥណទានធ្វេសប្រហែសក្នុងការបំពេញឯកសារ
- និយាយមិនច្បាស់លាស់ជាមួយអ្នកធានា ខ្លាចគេមិនធានាឱ្យ ខ្វះការគ្រប់គ្រង ការត្រួតពិនិត្យ និងការតាមដានលើការយឺតយ៉ាវក្នុងការសងប្រាក់មិនទាន់ពេលវេលា
- បង្ហាញពីភាពផ្តល់ការអនុគ្រោះសងប្រាក់ មិនមានផែនការច្បាស់លាស់ក្នុងការដោះស្រាយបំណុលទុកបំណុលរហូតក្លាយជាបំណុលគ្មានម្ចាស់
- បញ្ចេញឥណទានដើម្បីកាត់បន្ថយហានិភ័យ ឃុបឃិតជាមួយអតិថិជនកេងបន្លំឥណទាន។

៣.២.៣ កត្តាប្រធានសក្តិ

- **សេដ្ឋកិច្ច** : ការផ្ទុះឡើងនូវវិបត្តិសេដ្ឋកិច្ចពិភពលោក និងវិបត្តិហិរញ្ញវត្ថុជាដើម ។ កាលណាសេដ្ឋកិច្ចកើនឡើងធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រឈមនឹងការក្ស័យធន ព្រោះថាតម្រូវការឥណទានរបស់អតិថិជនមានការធ្លាក់ចុះដែលជាហេតុធ្វើឱ្យចំណូលរបស់គ្រឹះស្ថានមានការកាត់បន្ថយ ។
- **សង្គម** : ការផ្ទុះឡើងនៃសង្គ្រាម ការប្រែប្រួលសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល ឬគោលនយោបាយនានា ។
- **គ្រោះធម្មជាតិ** : ការជួបនូវគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ភ្លើងឆេះព្រៃនាំឱ្យអតិថិជនបាត់បង់លទ្ធភាពសង ដោយសារអាជីវកម្ម ឬមុខរបរត្រូវបានផ្អាកសំណើរការ។

## ៣.៣ យុទ្ធសាស្រ្តការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ

### ៣.៣.១ ការបង្កើតផែនការ

ក. ការចាត់ចែង

- ការបែងចែកការងាររបស់អនុប្រធានភ្នាក់ងារឥណទាន
- ការបែងចែកតំបន់ទទួលខុសត្រូវរបស់ភ្នាក់ងារឥណទាន
- ការបែងចែកតំបន់ទទួលខុសត្រូវរបស់ភ្នាក់ងារដោះស្រាយបំណុល។

ខ. ការដឹកនាំ

- ការដឹកនាំអនុប្រធាន និងភ្នាក់ងារឥណទានក្នុងការងារឥណទាន
- បែងចែកការងារឱ្យបានច្បាស់លាស់ទៅដល់អនុប្រធានដឹកនាំភ្នាក់ងារថ្មីក្នុងការចុះទំនាក់ទំនងជាមួយអាជ្ញាធរ
- ដឹកនាំការដោះស្រាយបំណុលដែលខកខានសងធ្ងន់ធ្ងរ
- ទប់ស្កាត់ហានិភ័យដែលកំពុងកើតមានឡើង
- បង្កើតក្រុមការងារដោះស្រាយបំណុល
- ផ្តល់ការហ្វឹកហ្វឺនដល់ភ្នាក់ងារដោះស្រាយបំណុលឱ្យមានជំនាញច្បាស់លាស់។

គ.ការត្រួតពិនិត្យ

- របាយការណ៍ត្រួតពិនិត្យលើបរិមាណនិងគុណភាពឥណទាន ( Quality Portfolio Report )
- ការចុះធ្វើ Spot Check ទៅលើតំបន់ប្រតិបត្តិការ
- ជួបជាមួយភ្នាក់ងារឥណទានរៀងរាល់ព្រឹករំលឹកពីកិច្ចការឥណទានប្រចាំថ្ងៃ( Payment In Arrears )
- របាយការណ៍ Credit Monitoring Report
- ការវិភាគពីលទ្ធផលដែលបានដោះស្រាយ និងកម្រិតនៃការដោះស្រាយ
- សិក្សាពីមូលហេតុដែលដោះស្រាយមិនបានលទ្ធផល។

### ឃ.លំដាប់លំដោយនៃការដោះស្រាយ

- ដំណាក់កាលនៃការប្រមូលព័ត៌មាន
- ឯកសារព័ត៌មាន
- ត្រួតពិនិត្យគ្រប់ឯកសារឥណទានរបស់អតិថិជន រួមមានកិច្ចសន្យាខ្ចីប្រាក់កិច្ចសន្យាដាក់ធានា
- ប្រវត្តិសងប្រាក់ កិច្ចព្រមព្រៀងនានា និងលិខិតស្នាមពាក់ព័ន្ធ ផ្សេងៗទៀត
- ស្រាវជ្រាវព័ត៌មានពីភ្នាក់ងារឥណទានដែលធ្លាប់ទទួលខុសត្រូវលើអតិថិជន
- ប្រមូល និងរក្សាទុកព័ត៌មានដែលទាក់ទងនឹងការដោះស្រាយធ្លាប់ទទួលបាននូវជោគជ័យកន្លង។

### ង.ការចុះស្រាវជ្រាវដល់មូលដ្ឋាន

ភ្នាក់ងារទទួលបន្ទុកត្រូវចុះដល់មូលដ្ឋាន ដើម្បីទំនាក់ទំនងជាមួយអាជ្ញាធរ ជាមួយនោះដែលត្រូវប្រុងប្រយ័ត្នក្នុងការប្រមូលព័ត៌មានជាពិសេសមិនត្រូវធ្វើការប្រមូលព័ត៌មានណាដែលបង្កឱ្យមានផលប៉ះពាល់ដល់អតិថិជនបង្កជាទំនាស់ ឬជាការទម្លាយវិជ្ជាជីវៈឥណទាន ធ្វើឱ្យអតិថិជនមានហេតុផលប្តឹងបកមកវិញ។

### ច.វិភាគលើស្ថានភាពបំណុល

រាល់ព័ត៌មានទាំងអស់ដែលប្រមូលបានត្រូវធ្វើការវិភាគវាយតម្លៃដើម្បីបង្កើតឡើងនូវសេចក្តីសន្និដ្ឋានមួយដ៏ជាក់លាក់អំពីស្ថានភាពអ្នកខ្ចីប្រាក់ មុននឹងឈានដល់ការធ្វើការសម្រេចចិត្តបង្កើតយុទ្ធសាស្ត្រដោះស្រាយប្រកបដោយប្រសិទ្ធិភាព។

### ឆ.ការបង្កើតជម្រើសដំណោះស្រាយ

ការបង្កើតជម្រើសយុទ្ធសាស្ត្រដោះស្រាយ ត្រូវប្រែប្រួលតាមស្ថានជាក់ស្តែងរបស់អ្នកខ្ចីប្រាក់រួមមានជីវភាពរស់នៅ ស្ថានភាពហិរញ្ញវត្ថុ ទ្រព្យដាក់ធានា វប្បធម៌ប្រពៃណី ភូមិសាស្ត្រ និងពេលវេលា។ ការចេះប្រើប្រាស់ឱកាស ដើម្បីចាប់យកជម្រើសណាមួយមកដោះស្រាយដែលជាគន្លឹះជោគជ័យក្នុងការដោះស្រាយបញ្ហាភ្នាក់ងារឥណទាន និងភ្នាក់ងារដោះស្រាយបំណុលត្រូវបង្កើតនូវដំណោះស្រាយឱ្យបានច្រើន ដើម្បីងាយស្រួលជ្រើសរើសយកមកអនុវត្តន៍ឱ្យត្រូវទៅនឹងស្ថានភាពជាក់ស្តែងរបស់បញ្ហានីមួយៗ៖

- ធ្វើលិខិតរំលឹកឱ្យសងប្រាក់
- ចុះជួបអ្នកខ្ចីដល់ទីកន្លែងពន្យល់ណែនាំឱ្យគោរពពេលវេលាសងប្រាក់ដោយរំលឹកពីកិច្ចសន្យាខ្ចីប្រាក់ កិច្ចព្រមព្រៀង និងបណ្តុះបណ្តាល និងបណ្តុះវិន័យឥណទានឡើងវិញ
- ធ្វើកិច្ចសន្យាជាមួយអតិថិជន អ្នកធានា អ្នកដាក់ទ្រព្យធានាជំនួស រំលឹកកិច្ចសន្យាព្រមព្រៀង
- ធ្វើកិច្ចសន្យាតាមលក្ខខណ្ឌដែលអ្នកខ្ចីប្រាក់បានព្រមព្រៀងដូចជាដាក់ទ្រព្យធានាបន្ថែម ឬយល់ព្រមលក់ ឬអ្នកធានា សាច់ញាតិ ពាក់ព័ន្ធយល់ព្រមដោះស្រាយជំនួស
- សុំអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន
- ជម្រើសចុងក្រោយសុំការអនុញ្ញាតប្តឹងទៅតុលាការ
- មុននឹងធ្វើការសម្រេចចិត្តជ្រើសរើសយកដំណោះស្រាយណាមួយមកប្រើត្រូវវាយតម្លៃប្រសិទ្ធិភាព អត្ថប្រយោជន៍ និងផលប៉ះពាល់របស់វាឱ្យបានច្បាស់លាស់ជាមុនសិន។
- ការអនុវត្តចុះដោះស្រាយបំណុល

**មុននឹងដោះស្រាយបំណុល ភ្នាក់ងារទទួលខុសត្រូវត្រូវអនុវត្តន៍ដូចតទៅ៖**

- ត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុន
- រៀបចំឯកសារដែលពាក់ព័ន្ធ ឯកសារឥណទាន កិច្ចសន្យាបន្ថែមមានតួលេខច្បាស់លាស់ស្ដីពីបំណុល ប្រវត្តិនៃការសង និងប្រវត្តិដំណោះស្រាយ
- កំណត់ពេលវេលា និងទីកន្លែងសម្រាប់ធ្វើការដោះស្រាយ
- កំណត់អំពីគោលបំណងក្នុងការដោះស្រាយវត្ថុបំណងដែលចង់បាន គឺធ្វើឱ្យអតិថិជនសហការ ត្រៀមពាក្យ សម្ដីសម្រាប់ធ្វើការចរចារ ត្រូវនិយាយពីអ្វីខ្លះ (ការចរចារមានរបៀបលុះត្រាណា ភ្នាក់ងារស្គាល់ច្បាស់ពីស្ថានភាពអតិថិជន)
- រៀបចំឥរិយាបថ កាយវិការ សម្លៀកបំពាក់ តាំងអារម្មណ៍ឱ្យហ្នឹងហ្ន ស្ដាប់ហេតុផលរបស់អតិថិជន មិនត្រូវប្រទេឡាត និងធ្វើការបកស្រាយពន្យល់តាមលំដាប់លំដោយ
- ត្រូវផ្ដល់ព័ត៌មានជាមុនដល់អ្នកខ្ចី អ្នកស្នងមរតក អ្នកធានា អ្នកដាក់ធានាជំនួស
- ករណីត្រូវការមានអន្តរាគមន៍ពីអាជ្ញាធរដែនដីត្រូវចុះទៅជំនួសទំនាក់ទំនងផ្ទាល់ជាមួយអាជ្ញាធរមុនដើម្បីសុំការពិគ្រោះយោបល់ និងកិច្ចសហការ។

**ការចុះដោះស្រាយត្រូវអនុវត្តន៍តាមវិធីដូចខាងក្រោម៖**

- មិនតាមប្រភេទនៃបញ្ហា
- តាមប្រភេទនៃបញ្ហា
- រំលឹកអំពីការទទួលខុសត្រូវក្នុងការសងប្រាក់ដោយផ្អែកលើការបណ្ដុះបណ្ដាលវិន័យឥណទាន កិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាដាក់ធានា និងកិច្ចព្រមព្រៀងបន្ថែម
- បញ្ចុះបញ្ចូលលើកទឹកចិត្ត ដាក់សម្ពាធលើអតិថិជនអនុវត្តទៅតាមកិច្ចសន្យាខ្ចីប្រាក់
- បង្ហាញឱ្យអតិថិជនបានដឹងពីភាពទន់ភ្លន់របស់គ្រឹះស្ថានក្នុងការដោះស្រាយ
- ត្រូវធ្វើជាអ្នកស្ដាប់ដ៏ល្អពេលអតិថិជនកំពុងធ្វើការចរចារដោះស្រាយ
- រិះរកដំណោះស្រាយ សម្រុះសម្រួលចរចារផ្សេងទៀត ដើម្បីស្វែងរកចំណុចគោលដៅរួម
- ត្រូវជួបអ្នកធានា ក្រុមធានាឱ្យសងជំនួសតាមខ្លឹមសារនៃលិខិតធានា។ កិច្ចសន្យាបន្ថែមអ្នកខ្ចី ឬអ្នកធានា ក្រុមធានាត្រូវតែរៀបចំធ្វើឡើងដោយមានសាក្សីដឹងឮ ឬមានអាជ្ញាធរមូលដ្ឋានចូលរួមផង ហើយត្រូវរក្សាសំណុំឯកសាររបស់អតិថិជនទុក។

ករណីអនុវត្តដូចខាងលើនេះហើយបំណុលនៅតែមិនទាន់បានសង ភ្នាក់ងារត្រូវទទួលខុសត្រូវ (ភ្នាក់ងារឥណទាន ឬភ្នាក់ងារសម្ពាធឱ្យកាន់តែខ្លាំងក្លាជាងមុន ដូចជាជួបជាមួយសាច់ញាតិ បងប្អូនឱ្យសងជំនួស ឬពឹងលើអ្នកមានឥទ្ធិពល (មេភូមិ មេឃុំ/ចៅសង្កាត់) ដើម្បីឱ្យអ្នកខ្ចីប្រាក់សងបំណុល។

- រាល់ការដោះស្រាយត្រូវធ្វើតាមជំហាននីមួយៗឱ្យបានច្បាស់លាស់ និងមានកំណត់ហេតុរាល់ដំណោះស្រាយដោយមានសាក្សីដឹងឮ ឬមានអាជ្ញាធរចូលរួម

- ករណីសងដោយពន្យាពេលសងឱ្យត្រូវនឹងលទ្ធភាពនៃបំណុល ភ្នាក់ងារត្រូវពិនិត្យអំពីលទ្ធភាព និងប្រភពចំណូលនោះ បើសមស្របត្រូវទុកឱកាសឱ្យតាមដំណើរ។ ការដោះស្រាយត្រូវតែម៉ឺងម៉ាត់ និងមានមូលដ្ឋានច្បាស់លាស់ តែមិនត្រូវប្រឡើសបើសខុសក្រមសីលធម៌ឡើយ
- និយាយឱ្យត្រឹមត្រូវតាមកម្មវត្ថុ ងាយស្តាប់ ងាយយល់ មិនអូសបន្លាយ អត់ធ្មត់ចំពោះស្ថានភាពក្នុងពេលមិនទាន់ចុះសម្រុង ការជជែកមិនទាន់ស្រុះស្រួល និងមិនទាន់យោគយល់គ្នាមិនត្រូវចាកចេញពេលកំពុងដំណើរការដោះស្រាយដោយមានអារម្មណ៍គិតថាមិនទទួលបានលទ្ធផល
- ធ្វើការសង្ខេបបញ្ជាក់អំពីលទ្ធផលដោះស្រាយដែលបានព្រមព្រៀង ឬអានកិច្ចព្រមព្រៀង ថ្លែងអំណរគុណពេលដោះស្រាយបានសម្រេច។

**៣.៣.២ តាមដាន និងត្រួតពិនិត្យ**

- ភ្នាក់ងារទទួលខុសត្រូវ ត្រូវតាមដានលើរាល់បញ្ហាដែលបានដោះស្រាយដោយផ្អែកលើកិច្ចសន្យាទាំងឡាយដែលបានព្រមព្រៀងជាមួយអតិថិជនឱ្យបានត្រឹមត្រូវ
- ត្រូវធ្វើតារាងតាមដានទៅតាមកាលបរិច្ឆេទដែលអតិថិជនបានសន្យាសង
- ត្រួតពិនិត្យមើលការប្រែប្រួលបំណុលនៅក្នុង Payment In Arrears And Write Off Monitoring Report
- ករណីពិនិត្យឃើញថាអតិថិជនមិនបានគោរពតាមកិច្ចសន្យាត្រូវទៅជួបជាថ្មីម្តងទៀតដល់លំនៅឋាន ឬ អញ្ជើញមកជួបដល់ការិយាល័យគ្រឹះស្ថាន ឬស្នាក់ការភូមិ ឃុំ សង្កាត់ ដើម្បីរំលឹកពីការសងប្រាក់
- មិនត្រូវទុកបំណុលយឺតយ៉ាវ និងបំណុលលុបចេញពីបញ្ជីដោយគ្មានអ្នកទទួលខុសត្រូវ ក្លាយជាបំណុលគ្មានម្ចាស់ ឬគ្មានអ្នកទទួលសង និងត្រូវចាត់ចែងពេលវេលាតាមដានឱ្យបានច្បាស់លាស់
- ធ្វើការសន្និដ្ឋាន និងវាយតម្លៃសម្រាប់ដោះស្រាយបន្ត។ ក្នុងករណីដោះស្រាយបញ្ហាមួយមិនមានប្រសិទ្ធភាពត្រូវជ្រើសយកដំណោះស្រាយណាមួយផ្សេងទៀតមកជំនួស។ មានករណីខ្លះតម្រូវឱ្យភ្នាក់ងារទៅប្រមូលព័ត៌មាន និងវាយតម្លៃសភាពការណ៍ជាថ្មីម្តងទៀតដើម្បីប្រមូលព័ត៌មានបន្ថែម ។

**៣.៣.៣ នីតិវិធីនៃការដោះស្រាយបំណុល វិធីសាស្ត្រក្នុងការដោះស្រាយបំណុល**

- ការចុះដឹកនាំដោយផ្ទាល់ ណែនាំពីរបៀបដោះស្រាយ និងផ្តល់បទពិសោធន៍ដល់ភ្នាក់ងារដោះស្រាយបំណុលដែលមិនទាន់មានបទពិសោធន៍
- ត្រូវផ្តល់ចំណេះដឹង បច្ចេកទេសល្អៗដែលធ្លាប់ទទួលបានជោគជ័យ
- មានការហ្វឹកហ្វឺនជាប្រចាំដល់ភ្នាក់ងារដោះស្រាយបំណុលធៀបនឹងលទ្ធផលដែលទទួលបាន
- បង្កើតយុទ្ធសាស្ត្រ និងនីតិវិធីដោះស្រាយបំណុលដែលពិបាកប្រមូល
- គួរមានវិធានការតាមផ្លូវច្បាប់ ចំពោះអតិថិជនណាដែលមានលទ្ធភាព ហើយដោះស្រាយអស់គ្រប់មធ្យោបាយមិនទទួលបានលទ្ធផល និងអតិថិជនដែលជាមេខ្យល់
- ការប្រមូលបំណុលត្រូវមានសកម្មភាពជាប្រចាំជាមួយអតិថិជន បើទោះជាការប្រមូលនោះបានតិចតួចក៏ដោយ
- ធ្វើការសិក្សាពីសុពលភាពនៃសំណុំឯកសារដែលពាក់ព័ន្ធទាំងអស់

- សិក្សាពីទំហំទឹកប្រាក់ អ្នកខ្ចី អ្នករួមខ្ចី អ្នកធានា លទ្ធភាពរបស់អតិថិជន និងទ្រព្យដាក់ធានា
- សិក្សាស្វែងយល់ព័ត៌មានពីភ្នាក់ងារឥណទានដែលធ្លាប់ទទួលខុសត្រូវពីមុន
- រៀបចំផែនការដោះស្រាយបំណុល ជាមួយអតិថិជនទៅតាមដំណាក់កាល
- ធ្វើការបែងចែកចំណាត់ថ្នាក់បំណុលឱ្យបានត្រឹមត្រូវ
- ត្រូវចេះពឹងពាក់អាជ្ញាធរកម្រិតណាដែលមានឥទ្ធិពលទៅលើអតិថិជន
- ដំណាក់កាលចុងក្រោយនៃការដោះស្រាយកូនបំណុលដែលរំលោភលើកិច្ចសន្យាត្រូវធ្វើតាមច្បាប់។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ បង្កើតឡើងគឺដើម្បីសង្គមកម្ពុជាដែលប្រជាពលរដ្ឋទាំងឡាយមានឱកាសគ្រប់គ្រាន់និងស្មើភាពគ្នាក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គមដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេហើយអាចជួយជាវិភាគទានដ៏មានប្រយោជន៍ និងមានតម្លៃចំពោះការអភិវឌ្ឍប្រទេសជាតិ។ ជាពិសេសផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងសម្បូរបែបដល់អតិថិជនគ្រប់រូបជាពិសេសស្ត្រី និងគ្រួសារដែលមានចំណូលទាប ដើម្បីជួយសម្រេចបំណងប្រាថ្នាផ្នែកហិរញ្ញវត្ថុ និងជីវភាពដែលពួកគាត់ចង់បាន។ ការវិភាគលើចំណុចខ្លាំងលើការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ មានចំណុចខ្លាំងដូចខាងក្រោម៖

- មានការបែងចែកការងារជាក់លាក់សម្រាប់អនុប្រធានភ្នាក់ងារឥណទាន និងតំបន់ទទួលខុសត្រូវរបស់ភ្នាក់ងារឥណទាន និងភ្នាក់ងារដោះស្រាយបំណុល។ នេះបង្ហាញពីការបែងចែកការងារដែលមានប្រសិទ្ធភាព និងជួយកាត់បន្ថយការច្របូកច្របល់នៃតួនាទី និងភារកិច្ចរបស់មនុស្សពាក់ព័ន្ធ។
- មានការដឹកនាំល្អ និងការបែងចែកការងារជាក់លាក់របស់អនុប្រធាន និងភ្នាក់ងារឥណទានក្នុងការងារឥណទាន។ ការដឹកនាំនេះផ្តល់ឱ្យមានស្ថេរភាពក្នុងការងារ និងជួយកាត់បន្ថយហានិភ័យក្នុងការផ្តល់ឥណទាន។
- មានប្រព័ន្ធត្រួតពិនិត្យល្អ ដូចជារបាយការណ៍ត្រួតពិនិត្យគុណភាពឥណទាន និងការចុះធ្វើ Spot Check ដែលជាកត្តាសំខាន់ក្នុងការរក្សាគុណភាពនៃឥណទាន និងបញ្ហាហានិភ័យ។
- មានការវិភាគល្អលើស្ថានភាពបំណុលផ្អែកលើព័ត៌មានដែលបានប្រមូលស្រាវជ្រាវពីភ្នាក់ងារឥណទានមុនពេលធ្វើការសម្រេចចិត្តនេះបង្កើតជាសេចក្តីសន្និដ្ឋានដ៏ជាក់ស្តែងសម្រាប់ការបង្កើតយុទ្ធសាស្ត្រដោះស្រាយដែលមានប្រសិទ្ធភាព។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការបង្កើតជម្រើសដំណោះស្រាយជាច្រើនសម្រាប់ការដោះស្រាយបំណុល។ ដំណោះស្រាយទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃអ្នកខ្ចីប្រាក់ ដូចជាជីវភាពរស់នៅ ស្ថានភាពហិរញ្ញវត្ថុ និងវប្បធម៌ប្រពៃណី។
- មានការតាមដាន បណ្តុះត្រឹមត្រូវតាមកាលបរិច្ឆេទ និងកិច្ចសន្យាដែលបានព្រមព្រៀងជាមួយអតិថិជនដែលជួយធានាបានថាការដោះស្រាយបំណុលកំពុងដំណើរការទៅតាមផែនការដែលបានកំណត់។
- មានការបង្កើតនីតិវិធីដោះស្រាយបំណុលដែលបានត្រឹមត្រូវ និងច្បាស់លាស់ជាមួយនឹងការផ្តល់ចំណេះដឹង និងការហ្វឹកហ្វឺនជាប្រចាំដល់ភ្នាក់ងារដោះស្រាយបំណុលធៀបនឹងលទ្ធផលដែលទទួលបាន។
- ករណីដែលដោះស្រាយបញ្ហានៅតែមានបញ្ហា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកំណត់ឱ្យមានវិធានការច្បាប់សម្រាប់អតិថិជនដែលមិនសហការទៅតាមកិច្ចសន្យា។

- ការប្រើប្រាស់វិធីសាស្រ្តលើកទឹកចិត្ត និងបណ្តុះវិន័យឥណទានដើម្បីជំរុញអតិថិជនអនុវត្តតាមកិច្ចសន្យា ដែលជួយសន្សំពេលវេលា និងការបញ្ចុះបញ្ចូលអតិថិជនស្របទៅតាមកិច្ចសន្យា។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទោះបីជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ មានចំណុចខ្លាំង និងវិជ្ជមានច្រើនយ៉ាងណាក៏ដោយ ក៏មានចំណុចខ្វះខាតមួយចំនួនក្នុងការកែលម្អក្នុងការវិភាគលើចំណុចខ្សោយដែលបង្កើតហានិភ័យឥណទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ អាចកាត់ឱ្យយកចំណុចសំខាន់ៗនេះទៀតបានដូចជា៖

- ផ្តល់ប្រាក់កម្ចី តែមិនបានត្រួតពិនិត្យ និងសិក្សាច្បាស់ពីប្រភពប្រាក់ចំណូលត្រឹមត្រូវរបស់អតិថិជន ដើម្បីមានលទ្ធភាពក្នុងការសងប្រាក់ដល់គ្រឹះស្ថាន
- បុគ្គលិកមានភាពធ្វេសប្រហែសក្នុងការវាយតម្លៃប្រាក់កម្ចី និងវាយតម្លៃទ្រព្យបញ្ចាំខ្ពស់ហួសពីតម្លៃការពិត
- ខ្វះប្រព័ន្ធត្រួតពិនិត្យ (អ្នកគ្រប់គ្រងមិនបានដឹងពីបញ្ហាដែលកើតឡើងទាន់ពេលវេលា)
- ខ្វះការលើកទឹកចិត្តបុគ្គលិក( បុគ្គលិកមិនយកចិត្តទុកដាក់ក្នុងការជ្រើសរើសអតិថិជន ) និងគោលការណ៍នីតិវិធីក្នុងការផ្តល់កម្ចីមិនសូវតឹងរឹង (ខ្សោយក្នុងការជ្រើសរើសអតិថិជន ) ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ស្តីពី "**ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទាន**" យើងអាចធ្វើការសន្និដ្ឋានបានថា ការគ្រប់គ្រងហានិភ័យឥណទានពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់គ្រឹះស្ថាន ក៏ដូចជាធនាគារនានាក្នុងប្រទេសកម្ពុជា។ ទោះបីជាពិភពលោក ជាពិសេសប្រទេសកម្ពុជាបានជួបនូវវិបត្តិជំងឺកូវីត១៩ ក្នុងអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២១ក៏ពិតមែន ក៏ប៉ុន្តែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ បានរក្សានូវចំហររបស់ខ្លួនយ៉ាងរឹងមាំដើម្បីរក្សាទុកអតិថិជនមិនត្រឹមតែប៉ុណ្ណោះ អេ.អឹម.ខេ មានគោលការណ៍ និងនីតិវិធីច្បាស់លាស់ក្នុងការវិភាគទៅលើអតិថិជនមុននឹងធ្វើការសម្រេចចិត្តផ្តល់ឥណទាន។ លើសពីនេះទៅទៀតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ បានយកចិត្តទុកដាក់យ៉ាងចំពោះការគ្រប់គ្រងហានិភ័យនៅគ្រប់ដំណាក់កាលតាំងតែពីមុនពេលផ្តល់ឥណទាន រហូតដល់ក្រោយផ្តល់ឥណទានដោយបានតាមដានហានិភ័យឥណទានជាប្រចាំខែយ៉ាងល្អបំផុត។ ជាពិសេសគ្រឹះស្ថាន អេ.អឹម.ខេ បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីឥណទានវាយតម្លៃឥណទានមានបង្កើតគោលនយោបាយឥណទាន ដើម្បីការពារគ្រឹះស្ថានពីហានិភ័យក្នុងអំឡុងពេលផ្តល់ឥណទានព្រមទាំងមានយុទ្ធសាស្ត្រសម្រាប់ដោះស្រាយឥណទានដែលមានហានិភ័យបានទាន់ពេលវេលាផងដែរ ។

អាស្រ័យលើកត្តាទាំងនេះ បានសបញ្ជាក់ឱ្យឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ ពិតជាមានចំណេះដឹងនិងបទពិសោធន៍យ៉ាងច្បាស់លាស់ក្នុងការគ្រប់គ្រងហានិភ័យឥណទាន ដែលអាចធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ.អឹម.ខេ តាំងជំហរបានយ៉ាងយូរនឹងរឹងមាំព្រមទាំងទទួលបានការគាំទ្រពីប្រជាជនកម្ពុជាយ៉ាងច្រើនផងដែរ ។

## ៥.២ ការផ្តល់អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវលើការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយរបស់គ្រឹះស្ថាន អេ.អឹម.ខេ សាខាជម្ពូវ័ន្តរួចមកយើងខ្ញុំសង្កេតឃើញ ថាគ្រឹះស្ថាននៅមានចំណុចខ្វះខាតមួយចំនួនដូចជាបានរៀបរាប់ខាងលើ ដូចនេះដើម្បីជាការរួមចំណែកអភិវឌ្ឍន៍ និងកែលម្អឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងក្រុមយើងខ្ញុំសូមចូលរួមបញ្ចេញមតិយោបល់ខ្លះៗដូចខាងក្រោម៖

- **ការបណ្តុះបណ្តាលអតិថិជន:** ផ្តល់ការបណ្តុះបណ្តាលអតិថិជនអំពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រាក់កម្ចីយ៉ាងមានប្រសិទ្ធភាព។
- **ការត្រួតពិនិត្យ និងបណ្តុះបណ្តាលបុគ្គលិក :** រៀបចំការបណ្តុះបណ្តាលបុគ្គលិកលើការវាយតម្លៃប្រាក់កម្ចី និងការគ្រប់គ្រងហានិភ័យ ដើម្បីធានាថាការសម្រេចចិត្តនឹងត្រឹមត្រូវ ។

- **ការវាយតម្លៃនិងជម្រើសអតិថិជន :** ប្រើប្រាស់ប្រព័ន្ធវាយតម្លៃសមត្ថភាពក្នុងការទូទាត់ប្រាក់ (Credit Scoring) ដើម្បីបញ្ជាក់សមត្ថភាពហិរញ្ញវត្ថុ និងភាពស្មោះត្រង់របស់អតិថិជន។
- គ្រឹះស្ថានគួរមានប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលិក ដើម្បីឱ្យពួកគេបំពេញការងារបានល្អ មួយវិញទៀតគ្រឹះស្ថានគួរធ្វើការបណ្តុះបណ្តាលបុគ្គលិកអំពីផែនការ ក្នុងការជ្រើសរើសអតិថិជនបន្ថែម ដើម្បីឱ្យពួកគេមានសមត្ថភាពពេញលេញក្នុងការវិភាគមុននឹងផ្តល់ប្រាក់កម្ចីដល់អតិថិជន ។

# ឯកសារយោង

# ឯកសារយោង


- https://freshnewsasia.com
- https://corporatefinanceinstitute.com
- https://khemsarith.wordpress.com
- តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ – khemsarith (wordpress.com)
- Robert Cole Loan Misher, Credit Management, 11th Edition
- https://km.m.wiktionary.org
- https://www.denetim.com/km
- https://clubniset.wordpress.com
- https://marketbusinessnews-com.
- https://www.khsearch.com/qna/24819
- https://www.oxfordbibliographies.com.
- https://corporatefinanceinstitute.com.
- https://www-technofunc-com.
- អំពី អេ អឹម ខេ - AMK MFI Plc. (amkcambodia.com)
- របាយការណ៍ប្រចាំឆ្នាំ២០២១ AMK ទំព័រទី២០-៤១ (https://www.amkcambodia.com/en/annual-report/)
- https://sokly.yolasite.com/resources/Sarana%20Manage%20Credit.pdf
- https://khemsarith.wordpress.com
- https://ebooks.elibrary-rule.com/public/images/sarana_file/Thesis2019%20(26).pdf
- https://khemsarith.wordpress.com
- របាយការណ៍ប្រចាំឆ្នាំ២០២១ AMK ទំព័រទី១០៥-១១០ (https://www.amkcambodia.com/en/annual-report/)
- របាយការណ៍ប្រចាំឆ្នាំ២០២១ AMK ទំព័រទី១១៥-១២៦ (https://www.amkcambodia.com/en/annual-report/)

# ឧបសម្ព័ន

# ឧបសម្ព័ន្ធ




Head Office AMK Microfinance PLC in Cambodia

AMK Microfinance Plc at Chumpuwan Branch




សេវាអតិថិជន
Customer Service


AMK
គ្រប់តម្រូវការសេវាហិរញ្ញវត្ថុ
ត្រូវបានផ្ដល់ជូននៅកន្លែងតែមួយ
ONE STOP SHOP

សកម្មភាពជួបសាស្ត្រាចារ្យដឹកនាំដើម្បីប្រឹក្សាយោបល់









